# ឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំ ២០២១
# របស់ ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់

## របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ

# ផ្នែកទី ១

## ភាគហ៊ុនិក

## ក. រចនាសម្ព័ន្ធភាគហ៊ុនិក (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១)

### ១. ព័ត៌មានភាគហ៊ុនិក

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | | | |
| | | នីតិបុគ្គល | | | |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | | | |
| | | នីតិបុគ្គល | ១ | ១ | ០.០១ |
| ចាប់ពី៥% ដល់តិចជាង៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | | | |
| | | នីតិបុគ្គល | | | |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | | | |
| | | នីតិបុគ្គល | | | |
| ចាប់ពី៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | | | |
| | | នីតិបុគ្គល | | | |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | | | |
| | | នីតិបុគ្គល | ១ | ៥១៩.៩៩៩ | ៩៩,៩៩ |

## ខ. សិទ្ធិ និងការការពារសិទ្ធិភាគហ៊ុនិក

### ១. សិទ្ធិភាគហ៊ុនិក

ភាគហ៊ុនិក មានសិទ្ធិក្នុងការសម្រេចចិត្តនៅក្នុងមហាសន្និបាតភាគហ៊ុនិក ដោយមិនអាស្រ័យលើឋានៈ និងចំនួនហ៊ុន។ ក្រុមប្រឹក្សាភិបាលអាច ធ្វើមហាសន្និបាតភាគហ៊ុនិក នៅកន្លែងណាមួយ នៅក្នុង ឬក្រៅប្រទេសកម្ពុជា ឬតាមរយៈការជូនដំណឹងតាមអ៊ីមែល។

### ២. ការការពារសិទ្ធិរបស់ភាគហ៊ុនិក និងការអនុវត្ត

សិទ្ធិមូលដ្ឋានរបស់ភាគហ៊ុនិក រួមមាន៖

- សិទ្ធិក្នុងការបែងចែកភាគលាភ
- សិទ្ធិក្នុងការទទួលបានព័ត៌មានពាក់ព័ន្ធនឹងធនាគារ
- សិទ្ធិក្នុងការចូលរួម និងបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ។

សិទ្ធិភាគហ៊ុនិក ត្រូវបានការពារដោយក្រុមប្រឹក្សាភិបាល និងខ្លឹមសារចែងនៅក្នុងជំពូកទីបីនៃលក្ខន្តិកៈរបស់ធនាគារ ABA។ យោងទៅតាមប្រការ ១៦ (១) នៃលក្ខន្តិកៈធនាគារ ABA “ភាគហ៊ុនិកម្នាក់ៗត្រូវមានសំឡេងឆ្នោតមួយ (១) សម្រាប់ហ៊ុននីមួយៗដែលខ្លួនកាន់កាប់”។

### ៣. ការការពារសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច និងការអនុវត្ត

ភាគហ៊ុនិកត្រូវមានសិទ្ធិសមមូលទៅនឹងចំនួនហ៊ុន ដើម្បីបោះឆ្នោតដោយមិនមានការបង្ខិតបង្ខំ។ ភាគហ៊ុនិកភាគតិច មានសិទ្ធិក្នុងការស្វែងរកការកែតម្រូវ ឬការខូចខាតពីធនាគារ ក្នុងករណីមានការរំលោភបំពាកសិទ្ធិកើតមានឡើង។

## គ. មហាសន្និបាតភាគហ៊ុនិក

### ១. នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុនិក និងការបោះឆ្នោត

នីតិវិធីនៃមហាសន្និបាតភាគហ៊ុនិក និងការបោះឆ្នោត គឺអាស្រ័យតាមមាត្រា ២២៤ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ ដែលចែងថា "អភិបាលត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ នៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ។ របាយការណ៍នោះត្រូវមានទាំង៖

ក) របាយការណ៍ហិរញ្ញវត្ថុដែលប្រៀបធៀបរវាងឆ្នាំសារពើពន្ធបច្ចុប្បន្ន និងឆ្នាំសារពើពន្ធឆ្នាំមុន។

ខ) របាយការណ៍របស់សវនករ។

គ) ព័ត៌មានផ្សេងទៀត ដែលធ្វើទៅតាមស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងលទ្ធផលដែលទទួលបានពីប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលតម្រូវដោយលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ឬកិច្ចព្រមព្រៀងជាឯកច្ឆន្ទនៃម្ចាស់ហ៊ុន ។"

ហើយមាត្រា ១២ នៃអនុស្សរណៈរបស់ ABA និងលក្ខខន្តិកៈក្រុមហ៊ុន បានចែងថា"មហាសន្និបាតសាមញ្ញរបស់ម្ចាស់ភាគហ៊ុនត្រូវធ្វើឡើងក្នុងរយៈ ៦ខែបន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធនីមួយៗ។"

- ក្របខ័ណ្ឌនីតិវិធីនៃកិច្ចប្រជុំទូទៅប្រចាំឆ្នាំរបស់ភាគទុនិក

  នៅពេលរៀបចំកិច្ចប្រជុំមហាសន្និបាតប្រចាំឆ្នាំរបស់ភាគទុនិក ធនាគារត្រូវគោរពតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលកំណត់ព័ត៌មានដែលតម្រូវឲ្យបង្ហាញជូនភាគទុនិក ក៏ដូចជាប្រការនៃលក្ខន្តិកៈរបស់ធនាគារ ABA ដែលកំណត់ពីថេរវេលានៃការរៀបចំកិច្ចប្រជុំមហាសន្និបាតសាមញ្ញប្រចាំឆ្នាំរបស់ភាគទុនិក។

- កូរ៉ុម

  កូរ៉ុមសម្រាប់រៀបចំកិច្ចប្រជុំមហាសន្និបាតរបស់ភាគទុនិកត្រូវមានសមាជិកលើសពីហាសិបភាគរយ (៥០%) នៃភាគហ៊ុនដែលបានចេញ និងមិនទាន់លក់។ រាល់សេចក្តីសម្រេចនៃកិច្ចប្រជុំទូទៅរបស់ភាគទុនិកត្រូវអនុម័តដោយការបោះឆ្នោតបញ្ជាក់តាមមតិភាគច្រើននៃភាគហ៊ុន តំណាងនៅក្នុងកិច្ចប្រជុំដែលកូរ៉ុមមានវត្តមាន។

- ការជូនដំណឹងអំពីកិច្ចប្រជុំ

  ការជូនដំណឹងជាលាយលក្ខណ៍អក្សរត្រូវជម្រាបជូនភាគទុនិកជាសន្លឹក ឬហាតកូពី (Hard Copy) ក្នុងរយៈពេល ១៤ ថ្ងៃមុនកាលកំណត់ប្រជុំ។ ការជូនដំណឹងនេះ ត្រូវបញ្ជាក់ថ្ងៃ ពេលវេលា ទីកន្លែង និងគោលបំណងនៃកិច្ចប្រជុំឲ្យបានច្បាស់លាស់។

- អំឡុងពេលប្រជុំ និងដំណើរការបោះឆ្នោត

  ភាគទុនិកនីមួយៗមានមួយសំឡេងបោះឆ្នោត សម្រាប់ហ៊ុននីមួយៗដែលបានកាន់កាប់។ ភាគទុនិកអាចអនុវត្តការបោះឆ្នោតរបស់ពួកគេដោយអ្នកបោះឆ្នោតតំណាង។ ទោះជាយ៉ាងណាក៏ដោយ អ្នកបោះឆ្នោតតំណាងត្រូវតែផ្តល់ឯកសារដែលបញ្ជាក់ពីសិទ្ធិអំណាចរបស់ពួកគេក្នុងនាមជាអ្នកបោះឆ្នោតតំណាងជូនធនាគារ មិនឲ្យលើសពីការចាប់ផ្តើមនៃកិច្ចប្រជុំមហាសន្និបាតរបស់ភាគទុនិកនីមួយៗ។ កិច្ចប្រជុំមហាសន្និបាតរបស់ភាគទុនិកធ្វើឡើងតាមរយៈការអនុវត្តសេចក្តីសម្រេចសាពាចរដែលត្រូវចុះហត្ថលេខាយ៉ាងត្រឹមត្រូវដោយតំណាងភាគទុនិកទាំងអស់ដែលចូលរួមក្នុងកិច្ចប្រជុំ។ ច្បាប់ចម្លងអេឡិកត្រូនិកនៃសេចក្តីសម្រេចសាពាចរដែលបានចុះហត្ថលេខាត្រូវផ្ញើទៅភាគទុនិកក្នុងរយៈពេល ១៤ ថ្ងៃបន្ទាប់ពីកិច្ចប្រជុំ។

- បន្ទាប់ពីប្រជុំ

  ធនាគារត្រូវបន្តផ្តល់ព័ត៌មាន និងកាតព្វកិច្ចរាយការណ៍ក្រោមប្រកាសរបស់គណៈកម្មការមូលប្បទានបត្រកម្ពុជាលេខ ០០៧/១៨/ក.ម.ក/ប្រ.ក ស្តីពីការបង្ហាញព័ត៌មានសាជីវកម្មចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០១៨។

## ២. ព័ត៌មានមហាសន្និបាតភាគហ៊ុនិក

| លរ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | កូរ៉ុមនៃកិច្ចប្រជុំ | របៀបវារៈ | សេចក្ដីសម្រេច |
|---|---|---|---|---|---|
| ១ | ១៩ មេសា ២០២១ | សេចក្ដីសម្រេច | វត្តមាន | ការពិចារណា នៃរបាយការណ៍ ហិរញ្ញវត្ថុឆ្នាំ សារពើពន្ធប្រចាំឆ្នាំ របស់ធនាគារ ABA សម្រាប់ដំណាច់ឆ្នាំ ៣១ ធ្នូ ២០២០។ | i) មហាសន្និបាតម្ចាស់ភាគហ៊ុន ប្រចាំឆ្នាំ បានកត់សម្គាល់ និង ចាត់ទុកលទ្ធផលហិរញ្ញវត្ថុ ធនាគារ ABA សម្រាប់ឆ្នាំ សារពើពន្ធ ២០២០ ប្រកបដោយ ភាពវិជ្ជមាន។<br>i) មហាសន្និបាតម្ចាស់ភាគហ៊ុន ប្រចាំឆ្នាំ បានអនុម័ត របាយការណ៍ហិរញ្ញវត្ថុដែលត្រូវ បានធ្វើសវនកម្មរួច របស់ធនាគារ ABA សម្រាប់ដំណាច់ឆ្នាំ ៣១ ធ្នូ ២០២០។ |

# ក. ការបែងចែកភាគលាភ

## ១. គោលនយោបាយបែងចែកភាគលាភ

គោលនយោបាយបែងចែកភាគលាភរបស់ធនាគារ ABA គឺអាស្រ័យតាម សេចក្ដីប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-០៤-០០៦ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៤ និងលក្ខន្តិកៈនៃធនាគារ ABA។ ធនាគារ មិនបានបែងចែកភាគលាភក្នុង ឆ្នាំ ២០២១។

ចន្លោះនេះទុកទំនេរ

# ផ្នែកទី ២

## ក្រុមប្រឹក្សាភិបាល

# ក. ក្រុមប្រឹក្សាភិបាល

## ១. សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់អាណត្តិ[១] |
|---|---|---|---|---|
| ១ | លោក Yves Jacquot | ប្រធានក្រុមប្រឹក្សាភិបាល | ២៩ មីនា ២០១៦ | ២៩ មីនា ២០២២ |
| ២ | លោក Dominic Jacques | អភិបាលមិនប្រតិបត្តិ | ២៩ មីនា ២០១៦ | ២៩ មីនា ២០២២ |
| ៣ | លោក Madi Akmambet | អភិបាលប្រតិបត្តិ | ២៦ កក្កដា ២០១២ | ២៦ កក្កដា ២០២៤ |
| ៤ | លោក Martin Ouellet | អភិបាលមិនប្រតិបត្តិ | ០៤ វិច្ឆិកា ២០១៩ | ០៤ វិច្ឆិកា ២០២២ |
| ៥ | លោក Paolo Pizzuto | អភិបាលមិនប្រតិបត្តិ | ១២ វិច្ឆិកា ២០២០ | ១២ វិច្ឆិកា ២០២៣ |
| ៦ | លោក Christian St-Arnaud | អភិបាលមិនប្រតិបត្តិ | ៣១ ធ្នូ ២០១៩ | ៣១ ធ្នូ ២០២២ |
| ៧ | លោក Etienne Chenevier | អភិបាលឯករាជ្យ | ២៦ មិថុនា ២០១៤ | ២៦ មិថុនា ២០២៣ |
| ៨ | លោក Henri Calvet | អភិបាលឯករាជ្យ | ២៩ មីនា ២០១៦ | ២៩ មីនា ២០២២ |
| ៩ | លោក Guy Quaden | អភិបាលឯករាជ្យ | ១៩ មិថុនា ២០១៩ | ១៩ មិថុនា ២០២២ |

[១] តាមខ្លឹមសារចែងក្នុងលក្ខខណ្ឌយោងនៃអភិបាលកិច្ចក្រុមប្រឹក្សាភិបាល ABA អាណត្តិនៃសមាជិកនីមួយៗរបស់ក្រុមប្រឹក្សាភិបាល ត្រូវមានរយៈពេល បី (៣)ឆ្នាំ ហើយនឹងត្រូវបន្តដោយស្វ័យប្រវត្តិ រហូតដល់ និងលុះត្រាតែមានការកំណត់ដោយការសម្រេចចិត្តពីម្ចាស់ភាគហ៊ុនរបស់ធនាគារ។

## ២. ជីវប្រវត្តិសង្ខេបរបស់អភិបាលនីមួយៗ

*លោក Yves Jacquot*
*ប្រធានក្រុមប្រឹក្សាភិបាល*

អគ្គនាយករងជាន់ខ្ពស់ — ទទួលបន្ទុកអភិវឌ្ឍន៍អន្តរជាតិ នៃក្រុមហ៊ុន វិនិយោគអន្តរជាតិ Natcan (ធនាគារកាណាដា)

លោក Yves Jacquot បានបញ្ចប់ការសិក្សាពីសាលា ESSEC នៅប្រទេសបារាំង។ នៅចន្លោះឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩៣ លោកបានកាន់មុខតំណែងផ្សេងៗជាច្រើនដែលរួមមានមុខតំណែងជាអគ្គនាយកនៅក្នុងធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ នៅប្រទេសបារាំង ក៏ដូចជានៅក្នុងវិស័យធនាគារសម្រាប់រូបវន្ត ទីផ្សារវិនិយោគ និងហិរញ្ញវត្ថុ ព្រមទាំងនៅក្នុងវិស័យគ្រប់គ្រងទ្រព្យសកម្មផងដែរ។ លោកបានចូលបម្រើការងារនៅ BRED Banque Populaire កាលពីឆ្នាំ១៩៩៣ ហើយបន្ទាប់មកលោកបានក្លាយជាអគ្គនាយករងនៃធនាគារនេះ និងជាអគ្គនាយកនៃធនាគារ COFIBRED ជាក្រុមហ៊ុនដែលកាន់កាប់ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនមេ។ ជាពិសេស លោកគឺជាប្រធានផ្នែកហិរញ្ញវត្ថុ ព័ត៌មានវិទ្យា អ្នកគ្រប់គ្រងការិយាល័យផ្ទៃក្នុងទាំងអស់ និងជាប្រធានផ្នែករដ្ឋបាលទូទៅរបស់ធនាគារផងដែរ។ លើសពីនេះទៀត លោកបានទទួលតំណែងជាអនុប្រធានគណៈកម្មាធិការឥណទាន និងជាប្រធានគណៈកម្មាធិការហិរញ្ញវត្ថុ ព្រមទាំងជាប្រធានគណៈកម្មាធិការគ្រប់គ្រងហានិភ័យសម្រាប់ក្រុមហ៊ុនបុត្រសម្ព័ន្ធផងដែរ។ លោកបានគ្រប់គ្រងសកម្មភាពសំខាន់ៗរបស់ធនាគារនេះនៅក្នុងវិស័យទូទាត់ និងបានទទួលបន្ទុកលើផ្នែកបទពិសោធច្នៃប្រឌិតផងដែរ។

លោក Jacquot ក៏បានលើកកម្ពស់ និងគ្រប់គ្រងកំណើនខាងក្រៅរបស់ក្រុមហ៊ុនមេទាំងនៅក្នុងប្រទេសបារាំង និងក្រៅប្រទេសបារាំងផងដែរ ដូចជានៅអឺរ៉ុប អាស៊ីប៉ាស៊ីហ្វិក និងអាហ្វ្រិកជាដើម។

*លោក Dominic Jacques*
*អភិបាលមិនប្រតិបត្តិ*

អគ្គនាយករង — ទទួលបន្ទុកអភិវឌ្ឍន៍អន្តរជាតិ (ធនាគារកាណាដា)

លោក Dominic Jacques បានបញ្ចប់ការសិក្សាពីសាលា HEC នៅប្រទេសកាណាដា។ លោកគឺជាគណនេយ្យករជាន់ខ្ពស់ (CPA, CA) និងជាអ្នកវិជ្ជាជីវៈ CFA ផងដែរ។

លោក Jacques កាន់មុខតំណែងជាអនុប្រធានផ្នែកអភិវឌ្ឍន៍អន្តរជាតិនៅធនាគារជាតិកាណាដា។ ក្នុងមុខតំណែងនេះ លោកទទួលបន្ទុកផ្នែកគ្រប់គ្រងផលបត្រវិនិយោគអន្តរជាតិរបស់ធនាគារ និងផ្នែកអភិវឌ្ឍន៍ឱកាសអាជីវកម្មផ្សេងៗ។

លោក Jacques បានចាប់ផ្ដើមអាជីពជាសវនករនៅក្រុមហ៊ុន PriceWaterhouseCoopers។ លោកត្រូវបានតែងតាំងជាអ្នកគ្រប់គ្រងជាន់ខ្ពស់ ផ្នែកសេវាប្រតិបត្តិការក្នុងឆ្នាំ២០០៨។ តាមរយៈមុខតំណែងនេះ លោកទទួលបន្ទុកផ្នែកត្រួតពិនិត្យវាយតម្លៃ និងប្រឹក្សាយោបល់អំពីការបញ្ចូល និងទិញអាជីវកម្ម (M&A)។ លោក Jacques បានចូលបម្រើការងារនៅធនាគារជាតិកាណាដាក្នុងឆ្នាំ២០១០ ក្នុងតំណែងជាអ្នកគ្រប់គ្រងជាន់ខ្ពស់ក្នុងក្រុមអភិវឌ្ឍន៍យុទ្ធសាស្ត្រ និងក្រុមហ៊ុន។ ក្នុងមុខតំណែងនេះ លោកជាអ្នកផ្ដល់ការប្រឹក្សាយោបល់ដល់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ធនាគារអំពីគំនិតផ្ដួចផ្ដើមជាយុទ្ធសាស្ត្រ ភាពជាដៃគូ និងសកម្មភាព M&A ផងដែរ។

លោក Jacques មានចំណេះដឹងខ្ពង់ខ្ពស់លើវិស័យធនាគារ ដោយមានបទពិសោធរយៈពេល១៥ឆ្នាំលើការងារផ្ដល់យោបល់ផ្នែកប្រតិបត្តិការ និងភាពជាដៃគូដល់គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ។ ក្នុងរយៈពេលនោះ លោកបានបម្រើការងារនៅទីក្រុងម៉ុងរ៉េអាល់ ទីក្រុងឡុងដ៍ ទីក្រុងប៉ារីស និងនៅ Silicon Valley (សហរដ្ឋអាមេរិក) ផងដែរ។

*លោក Madi Akmambet*
*អភិបាលប្រតិបត្តិ*

លោក Madi Akmambet មានសញ្ញាបត្រ MBA កម្រិតប្រតិបត្តិចំណាត់ថ្នាក់ល្អពីសាលា Cass Business School, សាកលវិទ្យាល័យ City University London (ឆ្នាំ ២០១៣) និងសញ្ញាបត្រសេដ្ឋកិច្ចពី Kazakh State Academy of Management (ឆ្នាំ ១៩៩៦)។

លោកបានចាប់ផ្ដើមអាជីពការងារនៅឆ្នាំ១៩៩៧ ក្នុងនាយកដ្ឋានរតនាគារនៃក្រសួង ហិរញ្ញវត្ថុរបស់សាធារណរដ្ឋកាហ្សាក់ស្ថាន ហើយបន្ទាប់មកទៀត លោកដូរទៅនាយកដ្ឋានត្រួតពិនិត្យធនាគារក្នុងធនាគារជាតិនៃកាហ្សាក់ស្ថាន។

ចន្លោះពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៧ លោកបានកាន់តួនាទីជាថ្នាក់ដឹកនាំជាន់ខ្ពស់នៅតាមបណ្ដាក្រុមហ៊ុន, សមាគមនៃគ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារពាណិជ្ជនៅកាហ្សាក់ស្ថាន។

បទពិសោធការងារអន្តរជាតិរបស់លោក ចាប់ផ្ដើមក្នុងឆ្នាំ២០០៧ ជាមួយគម្រោងអាជីវកម្មនានាក្នុងប្រទេសអ៊ុយបេគីស្ថាន ដែលគ្រប់គ្រងដោយ Visor Holding ដែលជាក្រុមហ៊ុនមូលធនឯកជនដែលមានមូលដ្ឋាននៅប្រទេសកាហ្សាក់ស្ថាន។

នៅខែមីនា ឆ្នាំ២០០៩ លោកត្រូវបានតែងតាំងជានាយកប្រតិបត្តិរបស់ធនាគារ ABA នៅប្រទេសកម្ពុជា ដែលលោកបាននាំមកនូវការផ្លាស់ប្ដូរដ៏សំខាន់ដល់ធនាគារ។ តាំងពីឆ្នាំ២០១២ មក លោកបានកាន់តួនាទីជាអភិបាលប្រតិបត្តិនៃក្រុមប្រឹក្សាភិបាលនៃធនាគារ ABA។

*លោក Martin Ouellet*
*អភិបាលមិនប្រតិបត្តិ*

ដោយបានបញ្ចប់ការសិក្សាពីសាលា École des Hautes Études Commerciales នៅទីក្រុងម៉ុងរ៉េអាល់ លោក Martin Ouellet គឺជាអ្នកឯកទេសគ្រប់គ្រងរតនវត្ថុមួយរូប ដែលបានចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងសន្ទនីយភាព និងឥណទាន រួមទាំងការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងអត្រាការប្រាក់ និងសេវាកម្មប្ដូរប្រាក់បរទេស។ បន្ទាប់ពីបានចាប់ផ្ដើមអាជីពក្នុងឆ្នាំ ១៩៧៧ ជាមួយ Crédit Foncier Franco-Canadien និងធនាគារម៉ុងរ៉េអាល់ លោកបានបម្រើការងាររយៈពេល ៣០ឆ្នាំ នៅធនាគារជាតិកាណាដា ជាកន្លែងដែលលោកបានឡើងតំណែងទៅកាន់តួនាទីជាអគ្គនាយករងជាន់ខ្ពស់ និងជាហេរញ្ញិកសាជីវកម្ម។ លោកបានកាន់តំណែងជាច្រើនទៀតនៅម៉ុងរ៉េអាល់, តូរ៉ុនតូ, និងទីក្រុងឡុងដ៍។

បច្ចុប្បន្ននេះ លោក Martin កំពុងកាន់តំណែងជាប្រធានសាជីវកម្មមួយរូប។ នៅក្នុងសមត្ថភាពនេះ លោកកាន់តួនាទីនៅក្នុងប្រឹក្សាភិបាលនៃគ្រឹះស្ថានជាច្រើន ដែលក្នុងនោះមាន Auditing and Assurance Standards Oversight Council (កាណាដា) និង Assurance-vie Banque Nationale។ លោក គឺជាសមាជិកនៃប្រឹក្សាភិបាល និងប្រធានគណៈកម្មាធិការមូលធន និងហានិភ័យរបស់ Haventree Bank ដែលជាធនាគារមួយនៅកាណាដា មានឯកទេសក្នុងការផ្តល់ជម្រើសឥណទាននិក្ខេបក្នុងស្រុក។ លោកជាសមាជិកគ្រឹះស្ថាននៃប្រធានសាជីវកម្ម (កាណាដា)។

លោក Martin ក៏ជាសមាជិកអង្គភាព Honour Circle របស់គ្រឹះស្ថានវប្បធម៌ Orchestre Symphonique de Montréal។

**លោក Christian St-Arnaud**
*អភិបាលមិនប្រតិបត្តិ*

លោក Christian St-Arnaud បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ The École des Hautes Études Commerciales ទីក្រុងម៉ុងរ៉េអាល់ ប្រទេសកាណាដា។ ចន្លោះឆ្នាំ ១៩៨៣ និង ២០០៩ លោកបានកាន់មុខតំណែងជាច្រើននៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុកាណាដា និងអន្តរជាតិ នៅប្រទេសកាណាដា ដោយផ្តោតលើទីផ្សារដើមទុនឥណទាន។

លោក Christian St-Arnaud បានចូលបម្រើការងារនៅធនាគារជាតិកាណាដា ក្នុងឆ្នាំ ២០០៩ ក្នុងតំណែងជាអនុប្រធានផ្នែកទីផ្សារដើមទុនឥណទាន និងអចលនទ្រព្យ ហើយត្រូវបានតែងតាំងជាអនុប្រធានជាន់ខ្ពស់ផ្នែកឥណទាន ក្នុងឆ្នាំ ២០១២ ទទួលបន្ទុកផ្នែកប្រតិបត្តិការបម្រើសេវាដល់អតិថិជនជារូបវន្ត, ពាណិជ្ជកម្ម, និងឥណទានទីផ្សារហិរញ្ញវត្ថុរបស់ធនាគារ រួមមានការវាយតម្លៃ, ការគ្រប់គ្រងផលបត្រ, និងអភិវឌ្ឍន៍គំរូឥណទាន។ លោកក៏ធ្លាប់ជាសមាជិកនៃគណៈកម្មាធិការជាន់ខ្ពស់ជាច្រើនរបស់ធនាគារផងដែរ រួមមាន គណៈកម្មាធិការហានិភ័យសកល, គណៈកម្មាធិការគ្រប់គ្រងហានិភ័យ, និងគណៈកម្មាធិការត្រួតពិនិត្យគំរូ។

**លោក Paolo Pizzuto**
*អភិបាលមិនប្រតិបត្តិ*

លោក Paolo Pizzuto បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ Université du Québec à Montréal ក្នុងឆ្នាំ២០០៣ ដោយទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម។

ការងារជាធនាគារិក លោកបានចូលរួមជាមួយធនាគារជាតិកាណាដា ក្នុងឆ្នាំ ១៩៨៦ ជាទីដែលលោកបានកាន់មុខតំណែងថ្នាក់គ្រប់គ្រងផ្សេងៗជាច្រើននៅក្នុងធនាគារនេះ រហូតដល់ឆ្នាំ ២០០១ ជាពេលដែលលោកត្រូវបានតែងតាំងជាអនុប្រធានផ្នែកលក់ និងសេវាកម្ម។

នៅឆ្នាំបន្ទាប់ៗមកទៀត លោកទទួលបានមុខតំណែងផ្នែកប្រតិបត្តិផ្សេងៗជាច្រើនទៀត រួមមាន សេវាធនាគាររូបវន្ត សេវាធនាគារពាណិជ្ជកម្ម ដំណោះស្រាយការទូទាត់ ការអភិវឌ្ឍដំណើរការ និងព័ត៌មានវិទ្យា។

ពីឆ្នាំ ២០០៩ ដល់ ២០១៥ លោកទទួលខុសត្រូវក្នុងការរៀបចំឡើងវិញនូវវិស្វកម្មដំណើរការពេញលេញសំខាន់ៗទូទាំងបណ្តាញធុរកិច្ចដោយដាក់ឲ្យប្រើប្រាស់នូវដំណោះស្រាយបង្កើតថ្មីៗ និងរំហូរការងារស្វ័យប្រវត្តិ ព្រមទាំងដឹកនាំកម្មវិធីទំនើបកម្មផ្សេងៗជាច្រើនដើម្បីបង្កើនប្រសិទ្ធភាពទូទាំងធនាគារ និងបទពិសោធអតិថិជន។

ចាប់ពីឆ្នាំ ២០១៥ លោក Pizzuto បានកាន់តំណែងជាអនុប្រធានជាន់ខ្ពស់ផ្នែកសេវាធនាគាររូបវន្តនៅប្រទេសកាណាដា។ លោកក៏កាន់តួនាទីជាប្រធានក្រុមប្រឹក្សាភិបាល Natbank ដែលជាធនាគារសហរដ្ឋអាមេរិកនៅក្នុងរដ្ឋផ្លរីដា និងជាអភិបាលស្តីទីរបស់ Canadian Italian Foundation ចាប់ពីឆ្នាំ ២០០៤។

លោក Paolo Pizzuto បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ ABA ក្នុងឆ្នាំ ២០២០។

***លោក Etienne Chenevier***
*អភិបាលអភិបាលឯករាជ្យ*

ដោយបានបញ្ចប់ការសិក្សាពីសាលា Ecole Polytechnique និងសាលា Ecole des Ponts et Chaussées នៅប្រទេសបារាំង លោក Etienne បានចាប់ផ្តើមអាជីពរបស់លោកនៅក្រសួងឧស្សាហកម្មបារាំង (ជាពិសេសគឺជា ប្រធានការិយាល័យវិនិយោគបរទេស)។ បន្ទាប់មក លោក Etienne បានចូលរួមក្នុងក្រុមហ៊ុន Air Liquide Group ដែលលោកបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៣ ដែលជាប្រតិបត្តិការអាជីវកម្មដំបូងនៅក្នុងប្រទេសចិន មុនពេលលោកត្រូវបានប្រគល់ភារកិច្ចចុះកិច្ចសន្យា

ផ្គត់ផ្គង់ឧស្ម័នឧស្សាហកម្មទ្រង់ទ្រាយធំដល់វិស័យដែកនៅក្នុងតំបន់អាស៊ី។ បន្ទាប់មកទៀត លោក Etienne បានចូលរួមក្នុងក្រុមហ៊ុន Rio Tinto ដែលនៅក្នុងក្រុមហ៊ុននោះលោកបានដឹកនាំការិយាល័យប្រចាំតំបន់អាស៊ីមានក្រុមហ៊ុនបុត្រសម្ព័ន្ធមួយដែលធ្វើឲ្យលោកមានឱកាសបង្កើត អភិវឌ្ឍ និងគ្រប់គ្រងលើប្រតិបត្តិការជាច្រើននៅក្នុងប្រទេសសិង្ហបុរី ប្រទេសអូស្ត្រាលី ប្រទេសចិន និងប្រទេសជប៉ុន។

បន្ទាប់មក លោកបានសហការជាដៃគូជាមួយក្រុមហ៊ុនមូលធនឯកជនបារាំង CityStar ដើម្បីបង្កើតការិយាល័យប្រចាំតំបន់អាស៊ីរបស់ខ្លួននៅក្នុងឆ្នាំ២០០៥ ដែលលោកជាដៃគូ និងជានាយក។ បច្ចុប្បន្នក្រុមហ៊ុន CityStar Private Equity Asia បង្កើតគម្រោងវិនិយោគធំៗជាច្រើននៅប្រទេសកម្ពុជាក្នុងវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច។

លោក Etienne បានមករស់នៅតំបន់អាស៊ីតាំងពីឆ្នាំ ១៩៩៣ ហើយលោកស្នាក់នៅប្រទេសសិង្ហបុរី និងប្រទេសកម្ពុជា។

*លោក Henri Calvet*
*អភិបាលឯករាជ្យ*

គុណវុឌ្ឍន៍៖ លោកបានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ Ecole Normale Supérieure de Cachan និងសញ្ញាបត្រថ្នាក់សាកលវិទ្យាល័យ (ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ចនៃសាកលវិទ្យាល័យ Paris-I Panthéon-Sorbonne)។

លោក Henri Calvet គឺជាស្ថាបនិកក្រុមហ៊ុន H2C CONSEIL ដែលផ្តល់សេវាប្រឹក្សាយោបល់ និង បណ្តុះបណ្តាលដល់គ្រឹះស្ថានឥណទាន និងក្រុមហ៊ុនមូលបត្រនៅក្នុងវិស័យសំខាន់ៗដូចជា៖ គណនេយ្យធនាគារ វិធានបង្ការ ការត្រួតពិនិត្យផ្ទៃក្នុង (រួមទាំងការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងការអនុវត្តច្បាប់ផងដែរ)។

មុនពេលបើកអាជីវកម្មផ្ទាល់ខ្លួន លោក Calvet បានបម្រើការងារអស់រយៈពេល ១០ឆ្នាំជាមួយនឹង គណៈកម្មការធនាគារបារាំង ហើយក្រោយមកទៀតបានធ្វើការនៅក្នុងធនាគារជាច្រើនដូចជា ក្រុមហ៊ុន Compagnie Financière Edmond de Rothschild Banque និងក្រុមហ៊ុន Compagnie Parisienne de Reescompte ជាដើម។

*លោក Guy Guaden*
*អភិបាលឯករាជ្យ*

លោក Guy Guaden បានបញ្ចប់ការសិក្សាផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសង្គម ពីសាកលវិទ្យាល័យ Liège (ប្រទេសបែលហ្ស៊ិក) និង La Sorbonne (ប្រទេសបារាំង)។ លោកបានទទួលសញ្ញាបត្របណ្ឌិតផ្នែកសេដ្ឋកិច្ចនៅសាកលវិទ្យាល័យ Liège ក្នុងឆ្នាំ ១៩៧៣។

លោក Quaden បានចាប់ផ្តើមអាជីពជាសាស្ត្រាចារ្យពេញម៉ោង នៅសាកលវិទ្យាល័យ Liège ក្នុងឆ្នាំ ១៩៧៧។ រវាងឆ្នាំ ១៩៨៧ ដល់ឆ្នាំ ១៩៨៨ លោកបានបម្រើការជាព្រឹទ្ធបុរស នៃមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច គ្រប់គ្រង និងសង្គម។

ចន្លោះឆ្នាំ ១៩៨៨ និងឆ្នាំ ១៩៩៦ លោកបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារជាតិបែលហ្ស៊ិក និងក្រោយមកត្រូវបានតែងតាំងជាអគ្គស្នងការ ទទួលបន្ទុកផ្នែកប្រាក់អឺរ៉ូរបស់រដ្ឋាភិបាលបែលហ្ស៊ិក។ បន្ទាប់ពីទទួលបានជោគជ័យក្នុងតួនាទីរបស់ខ្លួន លោក Quaden ក៏បានក្លាយខ្លួនជាអភិបាលនៃធនាគារជាតិបែលហ្ស៊ិក (ធនាគារកណ្តាលរបស់ប្រទេស) ចាប់ពីឆ្នាំ ១៩៩៩ ដល់ ឆ្នាំ ២០១១។ ក្នុងអំឡុងពេលជាមួយគ្នានោះដែរ លោកក៏ជាសមាជិកក្រុមប្រឹក្សាអភិបាលរបស់ធនាគារកណ្តាលអឺរ៉ុប អភិបាល IMF ប្រចាំប្រទេសបែលហ្ស៊ិក និងជាសមាជិកក្រុមប្រឹក្សារបស់ធនាគារទូទាត់អន្តរជាតិផងដែរ។

លោក Quaden ទទួលបានមេដាយ «Officier de la Légion d'honneur» ពីប្រធានាធិបតីបារាំង Chirac (២០០១) និងទទួលបានការតែងតាំងឋានៈកិត្តិយសពីព្រះមហាក្សត្រ Albert II របស់ប្រទេសបែលហ្ស៊ិក(២០០៧)។

## ៣. តួនាទី កាតព្វកិច្ច និងការទទួលខុសត្រូវ និងការបំពេញការងាររបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានការទទួលខុសត្រូវជារួមសម្រាប់ធនាគារ រួមមានការត្រួតត្រាលើ ផ្នែកគ្រប់គ្រងការប្រតិបត្តិ ដោយអនុម័ត និងតាមដានការអនុវត្តគោលដៅយុទ្ធសាស្ត្រ ក្របខណ្ឌអភិបាលកិច្ច និងវប្បធម៌សាជីវកម្ម។ ជាក់ស្តែង ក្រុមប្រឹក្សាយ៉ាងហោចណាស់ ក៏ត្រូវ៖

- អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ យុទ្ធសាស្ត្រធុរកិច្ចនិងសាជីវកម្ម ផែនការធុរកិច្ច និងកញ្ចប់ថវិកាប្រចាំឆ្នាំ
- អនុម័តលើក្រមវិជ្ជាជីវៈ ហានិភ័យ ការប្រតិបត្តិតាម សវនកម្ម និងគោលនយោបាយសំខាន់ៗផ្សេងៗទៀតរបស់ធនាគារ

- តែងតាំងនាយកប្រតិបត្តិ និងអនុម័តការតែងតាំងក្រុមការងារប្រតិបត្តិសំខាន់ៗ ជាពិសេសក្នុងផ្នែកតាមដានការប្រតិបត្តិតាម និងសវនកម្មផ្ទៃក្នុង
- បង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងដែលអនុញ្ញាតឲ្យក្រុមការងារអនុវត្តតួនាទីទាន់ពេលវេលា និងពេញដោយការយល់ដឹងច្បាស់
- ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងទៀងទាត់ជាមួយ ផ្នែកគ្រប់គ្រងការប្រតិបត្តិ និងសវនកម្មផ្ទៃក្នុង
- វាយតម្លៃយុទ្ធសាស្ត្រ និងគោលនយោបាយធនាគារតាមកាលកំណត់ ពាក់ព័ន្ធនឹងការអនុវត្តជាក់ស្តែង និងការពង្រឹង និងអភិវឌ្ឍន៍បន្ថែម។

## ៤. ប្រសិនបើអភិបាលណាមួយជាអភិបាល ភាគហ៊ុនិក ឬម្ចាស់រួមនៃក្រុមហ៊ុនផ្សេង

| ល.រ | ឈ្មោះអភិបាល | ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ | អភិបាល/ភាគហ៊ុនិក/ម្ចាស់រួម |
|---|---|---|---|
| ១ | លោក Etienne Chenevier/លោក មាស សុវណ្ណ | WYSH Holdings Pte Ltd | ម្ចាស់ និងអភិបាល (ជាលោក Etienne Chenevier) |
| | | Cuauhtli Resources CRF 1 Pte Ltd | ម្ចាស់ និងអភិបាល (ជាលោក Etienne Chenevier) |
| | | Cuauhtli Resources Management Pte Ltd | ម្ចាស់ និងអភិបាល (ជាលោក Etienne Chenevier) |
| | | CityStar Group of Companies | ម្ចាស់ភាគហ៊ុនតូច (ជាលោក Etienne Chenevier) នៅក្នុងក្រុមហ៊ុន 6 របស់គ្រុប អភិបាលនៃក្រុមហ៊ុនទាំងអស់ (ជាលោក Etienne Chenevier ឬលោក មាស សុវណ្ណ អាស្រ័យលើក្រុមហ៊ុន) |
| | | CityStar Services Ream Co., Ltd | អភិបាល (ជាលោក Etienne Chenevier) |
| | | Koh Takiev Investment Co., Ltd | អ្នកតំណាងរបស់ភាគហ៊ុនិកតែមួយគត់ និងអភិបាល (ជាលោក Etienne Chenevier) |
| | | Koh Russey Resort Ltd | អ្នកតំណាងរបស់ភាគហ៊ុនិកតែមួយគត់ និងអភិបាល (ជាលោក Etienne Chenevier) |
| | | Koh Russey Hotel Ltd | អ្នកតំណាងរបស់ភាគហ៊ុនិកតែមួយគត់ (ជាលោក Etienne Chenevier) និងអភិបាល (ជាលោក មាស សុវណ្ណ) |
| | | Koh Russey Development Ltd | អ្នកតំណាងរបស់ភាគហ៊ុនិកតែមួយគត់ (ជាលោក Etienne Chenevier) និងអភិបាល (ជាលោក មាស សុវណ្ណ) |
| | | Koh Russey Middle Ltd | អ្នកតំណាងរបស់ភាគហ៊ុនិកតែមួយគត់ (ជាលោក Etienne Chenevier) និងអភិបាល (ជាលោក មាស សុវណ្ណ) |
| | | Koh Russey South Ltd | អ្នកតំណាងរបស់ភាគហ៊ុនិកតែមួយគត់ (ជាលោក Etienne Chenevier) និងអភិបាល (ជាលោក មាស សុវណ្ណ) |
| | | CityStar Phnom Penh Condos Ltd | ម្ចាស់ភាគហ៊ុនតូច (ជាលោក Etienne Chenevier) និងអភិបាល (ជាលោក មាស សុវណ្ណ) |

| ល.រ | ឈ្មោះអភិបាល | ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ | អភិបាល/ភាគហ៊ុនិក/ម្ចាស់រួម |
|---|---|---|---|
| | | CityStar Phnom Penh Residences Ltd | ម្ចាស់ភាគហ៊ុនតូច (ជាលោក Etienne Chenevier) និងអភិបាល (ជាលោក មាស សុវណ្ណ) |
| | | CityStar Phnom Penh Properties Ltd | ម្ចាស់ភាគហ៊ុនតូច (ជាលោក Etienne Chenevier) និងអភិបាល (ជាលោក មាស សុវណ្ណ) |
| | | CityStar Phnom Penh Villas Ltd | ម្ចាស់ភាគហ៊ុនតូច (ជាលោក Etienne Chenevier)និងអភិបាល (ជាលោក មាស សុវណ្ណ) |
| | | Asia Gourmet (Cambodia) Co., Ltd | ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់និងអភិបាល (ជាលោក មាស សុវណ្ណ) |
| ២ | លោក Guy Quaden | Byblos Bank Europe | អភិបាលឯករាជ្យ (ចប់អាណត្តិខែមេសា ២០២១) |
| ៣ | លោក Henri Calvet | H2C Conseil | អគ្គនាយក |
| ៤ | លោក Christian St-Arnaud | AfrAsia Bank Limited | អភិបាល |
| ៥ | លោក Martin Ouellet | Haventree Bank | អភិបាល |
| ៦ | លោក Paolo Pizzuto | NatBank | ប្រធានក្រុមប្រឹក្សាភិបាល |
| ៧ | លោក Madi Akmambet | Palmera (M) SDN. BHD. | អភិបាល និងភាគហ៊ុនិក |
| ៨ | លោក Dominic Jacques | NSIA Participations<br>NSIA Banque Cote d'Ivoire<br>ATA IT Ltd. | អភិបាល<br>អភិបាល<br>អភិបាល |
| ៩ | លោក Yves Jacquot | ATA IT<br>Xacbank និង TenGer<br>Byblos Bank | ប្រធានក្រុមប្រឹក្សាភិបាល<br>អភិបាល<br>អភិបាល |

## ៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលចូលរួមកិច្ចប្រជុំ |
|---|---|---|---|
| ១ | ២៥ មីនា | កិច្ចប្រជុំផ្ទាល់ ដោយមានការផ្សាយតាមប្រព័ន្ធវីដេអូ (សន្និសីទវីដេអូ) | Yves Jacquot<br>Dominic Jacques<br>Madi Akmambet<br>Martin Ouellet<br>Christian St-Arnaud<br>Paolo Pizzuto<br>Etienne Chenevier<br>Henri Calvet<br>Guy Quaden |
| ២ | ៩ មិថុនា | កិច្ចប្រជុំផ្ទាល់ ដោយមានការផ្សាយតាមប្រព័ន្ធវីដេអូ (សន្និសីទវីដេអូ) | Yves Jacquot<br>Dominic Jacques<br>Madi Akmambet<br>Martin Ouellet<br>Christian St-Arnaud<br>Paolo Pizzuto<br>Etienne Chenevier<br>Henri Calvet<br>Guy Quaden |
| ៣ | ១១ សីហា | កិច្ចប្រជុំផ្ទាល់ ដោយមានការផ្សាយតាមប្រព័ន្ធវីដេអូ (សន្និសីទវីដេអូ) | Yves Jacquot<br>Dominic Jacques<br>Madi Akmambet<br>Martin Ouellet<br>Christian St-Arnaud<br>Paolo Pizzuto<br>Etienne Chenevier<br>Henri Calvet<br>Guy Quaden |
| ៤ | ២៤ វិច្ឆិកា | កិច្ចប្រជុំផ្ទាល់ ដោយមានការផ្សាយតាមប្រព័ន្ធវីដេអូ (សន្និសីទវីដេអូ) | Yves Jacquot<br>Dominic Jacques<br>Madi Akmambet<br>Martin Ouellet<br>Christian St-Arnaud<br>Paolo Pizzuto<br>Etienne Chenevier<br>Henri Calvet<br>Guy Quaden |

## ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

### ១. រចនាសម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល

### ១.១. គណៈកម្មាធិការសវនកម្ម

| ល.រ | ឈ្មោះ | តំណែង | ចំនួនសមាសភាពចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|
| ១ | លោក Etienne Chenevier | ប្រធាន | ៤ | ៤ |
| ២ | លោក Henri Calvet | សមាជិក | ៤ | |
| ៣ | លោក Christian St-Arnaud | សមាជិក | ៤ | |
| ៤ | លោក Paolo Pizzuto | សមាជិក | ៤ | |

### តួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការសវនកម្ម ទទួលខុសត្រូវសម្រាប់ការបំពេញមុខងារសវនកម្មផ្ទៃក្នុង ដែលចាត់តាំងដោយក្រុមប្រឹក្សាភិបាល ដែលរួមមាន៖

*ទូទៅ*

- ត្រួតពិនិត្យតាមដាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងពិនិត្យលើរបាយការណ៍សវនកម្មផ្ទៃក្នុងជាមួយការរកឃើញកំហុស ហើយផ្តល់អនុសាសន៍
- ប្រជុំជាទៀងទាត់ជាមួយនាយកប្រតិបត្តិ ប្រធានអង្គភាពសវនកម្មផ្ទៃក្នុង និងប្រធានអង្គភាពផ្សេងៗទៀត ពាក់ព័ន្ធនឹងការរកឃើញកំហុសសវនកម្ម និងផ្តល់អនុសាសន៍
- បញ្ជូនសំណើ និងអនុសាសន៍ទៅក្រុមប្រឹក្សាភិបាល ដែលតម្រូវឲ្យមានការអនុម័តពីក្រុមប្រឹក្សាភិបាល។

*សវនករឯករាជ្យ*

- ការយល់ព្រមនៃផែនការរបស់សវនករឯករាជ្យ សម្រាប់ជាអនុសាសន៍ ឬព័ត៌មានរបស់ក្រុមប្រឹក្សាភិបាល
- ប្រជុំជាមួយសវនករឯករាជ្យតាមវីដេអូ
- ស្នើបេក្ខជនសម្រាប់សវកម្មឯករាជ្យ
- អនុម័តថ្លៃសេវាសវនកម្មប្រចាំឆ្នាំ សម្រាប់ជាអនុសាសន៍ ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- អនុម័តថ្លៃសេវា និងកិច្ចការផ្សេងៗមិនមែនសវនកម្ម។

*សវនកម្មផ្ទៃក្នុង*

- ការយល់ព្រមលើផែនការសវនកម្មផ្ទៃក្នុង សម្រាប់ជាអនុសាសន៍ ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- ត្រួតពិនិត្យរបាយការណ៍សវនកម្មផ្ទៃក្នុង
- បន្តតាមដានការកែប្រែកំហុសសវនកម្មផ្ទៃក្នុង
- ត្រួតពិនិត្យអាណត្តិ និងដែនកំណត់នៃមុខងារសវនកម្មផ្ទៃក្នុង
- អនុម័តគោលនយោបាយសវនកម្មផ្ទៃក្នុង សម្រាប់ជាអនុសាសន៍ ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- អនុម័តកញ្ចប់ថវិកាសម្រាប់មុខងារសវនកម្មផ្ទៃក្នុង សម្រាប់ជាអនុសាសន៍ ឬព័ត៌មានដល់ក្រុមប្រក្សាភិបាល
- ការវាយតម្លៃលើការអនុវត្តការងាររបស់នាយក/ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ

- ត្រួតពិនិត្យប្រចាំឆ្នាំលើលាភការប្រចាំឆ្នាំសម្រាប់សវនកម្មផ្ទៃក្នុង
- ប្រជុំជាមួយប្រធានអង្គភាពសវនកម្មផ្ទៃក្នុងតាមវីដេអូ
- ផ្តល់អនុសាសន៍លើបេក្ខជនសម្រាប់នាយកសវនកម្ម
- ត្រួតពិនិត្យ និងផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងហេតុផលដែលជាឫសគល់បង្កឲ្យមានការផ្លាស់ប្តូរ បញ្ចប់តួនាទី និងលាលែងរបស់នាយក/ប្រធានអង្គភាពសវនកម្មផ្ទៃក្នុង។

*និយតកម្ម*

- ត្រួតពិនិត្យរបាយការណ៍សវនកម្មពីនិយ័តករ
- បន្តតាមដានការកែប្រែកំហុសដែលនិយតករបានរកឃើញ។

*ហិរញ្ញវត្ថុ*

- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ប្រជុំជាមួយនាយកហិរញ្ញវត្ថុតាមវីដេអូ
- ផ្តល់អនុសាសន៍លើបេក្ខជនសម្រាប់នាយកហិរញ្ញវត្ថុ។

អ្នកទទួលការអញ្ជើញ (លើកលែងប្រធានក្រុមប្រឹក្សាភិបាល) និងអ្នកសង្កេតការណ៍ មិនចូលរួមកិច្ចប្រជុំតាមវីដេអូឡើយ។

## លទ្ធផលនៃការអនុវត្តការងាររបស់គណៈកម្មាធិការសវនកម្ម

ក្នុងឆ្នាំ ២០២១ គណៈកម្មាធិការសវនកម្ម ប្រារព្ធកិច្ចប្រជុំ ៤ ដែលត្រូវបានធ្វើឡើងរៀងរាល់ត្រីមាស។

សកម្មភាពដែលត្រូវបានធ្វើឡើងដោយគណៈកម្មាធិការមានដូចខាងក្រោម៖

- ពិភាក្សា និងដោះស្រាយការរកកំហុសពីសវនកម្មផ្ទៃក្នុង
- ពិភាក្សាលើសូចនាករសមិទ្ធកម្មគន្លឹះ (KPIs) សម្រាប់ក្រុមការងារសវនកម្មផ្ទៃក្នុង, បញ្ជាថវិកា និងបុគ្គលិក
- ពិនិត្យការអនុវត្តតាមអនុសាសន៍ពីនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងគណៈកម្មាធិការសវនកម្ម
- ពិភាក្សាលើការគណនាការខាតបង់ឥណទានរំពឹងទុកសម្រាប់ឥណទានរៀបចំឡើងវិញបណ្តាលមកពី ជំងឺកូវីដ
- ពិនិត្យរបាយការណ៍បណ្តុះបណ្តាលសម្រាប់សវនករផ្ទៃក្នុង
- បើកកិច្ចប្រជុំជាមួយសវនករ
- អនុម័តរបាយការណ៍ប្រចាំឆ្នាំជូននិយ័តករ
- ពិនិត្យ និងអនុម័តផែនការការងាររបស់សវនកម្មផ្ទៃក្នុងសម្រាប់ឆ្នាំ ២០២២
- អនុម័តការតែងតាំងសវនករឯករាជ្យ
- វាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំរបស់ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង

### ១.២. គណៈកម្មាធិការអភិបាលកិច្ច

| ល.រ | ឈ្មោះ | តំណែង | ចំនួនសមាសភាពចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|
| ១ | លោក Yves Jacquot | ប្រធាន | ៤ | ៤ |
| ២ | លោក Dominic Jacques | សមាជិក | ៤ | |
| ៣ | លោក Etienne Chenevier | សមាជិក | ៤ | |

## តួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការអភិបាលកិច្ច

ប្រកាសលេខ ធ-៧-០៨-២១១ ប្រក. ស្តីពីអភិបាលកិច្ចនៅក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដើម្បីពង្រឹងគ្រឹះស្ថានធនាគារដោយរៀបចំឲ្យមានការគ្រប់គ្រងតាមកម្រិតផ្សេងៗដូចជា ក្រុមប្រឹក្សាភិបាលឯករាជ្យ និងសកម្ម និងក្រុមប្រឹក្សាភិបាលប្រតិបត្តិ និងគណៈកម្មាធិការឯកទេសជាមួយគុណភាព សមត្ថភាព និងសុចរិតភាពសម្រាប់គ្រប់គ្រងគ្រឹះស្ថានប្រកបដោយប្រសិទ្ធភាព(មាត្រា១)។

ក្រុមប្រឹក្សាភិបាល តាមសេចក្តីសម្រេចកាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ បានសម្រេចដាក់ឲ្យដំណើរការគណៈកម្មាធិការអភិបាលកិច្ច។ គណៈកម្មាធិការអភិបាលកិច្ចណែនាំចាត់តាំងសមាជិកនៃគណៈកម្មាធិការនីមួយៗរបស់ក្រុមប្រឹក្សាភិបាល ដើម្បីទទួលការអនុម័តចុងក្រោយពីក្រុមប្រឹក្សាភិបាលរបស់ធនាគារ។

*ទូទៅ*

- ត្រួតពិនិត្យតាមដានលើការប្រតិបត្តិតាមរបស់ធនាគារជាមួយគោលការណ៍អភិបាលកិច្ចសាជីវកម្ម
- ផ្តល់អនុសាសន៍ដល់គោលនយោបាយក្រុមប្រឹក្សាភិបាល និងនីតិវិធី ដែលត្រូវបានបង្កើតដើម្បីផ្តល់ប្រសិទ្ធភាពអភិបាលកិច្ចសាជីវកម្ម រួមមានសំណើរៀបចំរចនាសម្ពន្ធ និងការបង្កើតគណៈកម្មាធិការក្រុមប្រឹក្សាភិបាល
- បញ្ជូនសំណើ និងអនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល ពាក់ព័ន្ធបញ្ហានានា ដែលត្រូវមានការអនុម័តពីក្រុមប្រឹក្សា។

*អភិបាលកិច្ចក្រុមប្រឹក្សាភិបាល*

- ត្រួតពិនិត្យ អាណត្តិ និងតួនាទីរបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការ ដើម្បីជាអនុសាសន៍ ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- ពិនិត្យ និងស្នើសមាជិកភាពគណៈកម្មាធិការ
- វាយតម្លៃ បេក្ខជនសម្រាប់សមាជិកថ្មីរបស់ប្រឹក្សាភិបាល ដើម្បីជាអនុសាសន៍ ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- ត្រួតពិនិត្យលាភការសមាជិកក្រុមប្រឹក្សាភិបាល ដើម្បីជាអនុសាសន៍ ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- ត្រួតពិនិត្យទំនាស់ផលប្រយោជន៍សមាជិកក្រុមប្រឹក្សាភិបាលដែលអាចកើតមាន
- ស្នើ និងបន្តតាមដានលើការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាភិបាល ដើម្បីជាអនុសាសន៍ ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- ត្រួតពិនិត្យការងារ D&O។

*នាយកប្រតិបត្តិ*

- ការអនុម័តកម្មវត្ថុរបស់នាយកប្រតិបត្តិ
- ការវាយតម្លៃការអនុវត្តរបស់នាយកប្រតិបត្តិ
- ការត្រួតពិនិត្យប្រចាំឆ្នាំនៃលាភការរបស់របស់នាយកប្រតិបត្តិ ដើម្បីជាអនុសាសន៍ ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល។

*ភាគីពាក់ព័ន្ធ*

- ត្រួតពិនិត្យ និងបន្តតាមដានជុំវិញប្រតិបត្តិការភាគីពាក់ព័ន្ធ។

*លាភការ*

- ការអនុម័តផែនការលាភការប្រចាំឆ្នាំ ដើម្បីជាអនុសាសន៍ ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- ការអនុម័តផែនការអត្ថប្រយោជន៍បុគ្គលិក ដើម្បីជាអនុសាសន៍ ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- ការអនុម័តលាភការប្រចាំឆ្នាំ ដើម្បីជាអនុសាសន៍ ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- ការអនុម័តលាភការសម្រាប់កម្រិតនាយក ដើម្បីជាអនុសាសន៍ ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល។

ធនធានមនុស្ស

- ផែនការបន្តតំណែងផ្នែកគ្រប់គ្រងជាន់ខ្ពស់
- ការជ្រើសរើសនិយោជិត។

អ្នកទទួលការអញ្ជើញ (លើកលែងប្រធានក្រុមប្រឹក្សាភិបាល) និងអ្នកសង្កេតការណ៍ មិនចូលរួមកិច្ចប្រជុំតាមវីដេអូឡើយ។

## លទ្ធផលនៃការអនុវត្តការងាររបស់គណៈកម្មាធិការអភិបាលកិច្ច

ក្នុងឆ្នាំ ២០២១ គណៈកម្មាធិការអភិបាលកិច្ច ប្រារព្ធកិច្ចប្រជុំ ៤ ដែលត្រូវបានធ្វើឡើងរៀងរាល់ត្រីមាស។

សកម្មភាពដែលត្រូវបានធ្វើឡើងដោយគណៈកម្មាធិការមានដូចខាងក្រោម៖

- ពិនិត្យព័ត៌មានលើប្រតិបត្តិការភាគីពាក់ព័ន្ធ
- ពិនិត្យរបាយការណ៍វិភាគ ថ្លៃចំណាយ/ចំណូល ដោយបណ្តាញធុរកិច្ច
- ពិភាក្សាលើការវិភាគក្រុមប្រឹក្សាភិបាល និងកិច្ចប្រជុំគណៈកម្មាធិការក្រុមប្រឹក្សាភិបាលក្នុងឆ្នាំ ២០២១ និងឆ្នាំ ២០២២
- ពិភាក្សាលើប្រាក់លើកទឹកចិត្តសម្រាប់ប្រធាននាយកដ្ឋាន និងផែនការដំឡើងតំណែង ABA សម្រាប់អ្នកមានសមត្ថភាព ឆ្នាំ ២០២១- ២០២២
- ពិភាក្សាលើថ្លៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសម្រាប់សមាជិកក្រុមប្រឹក្សាភិបាល។

### ១.៣. គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

| ល.រ | ឈ្មោះ | តំណែង | ចំនួនសមាសភាពចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|
| ១ | លោក Dominic Jacques | ប្រធាន | ៤ | ៤ |
| ២ | លោក Martin Ouellet | សមាជិក | ៤ | |
| ៣ | លោក Etienne Chenevier | សមាជិក | ៤ | |
| ៤ | លោក Guy Quaden | សមាជិក | ៤ | |

## តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

គណៈកម្មាធិការត្រូវបានបង្កើតឡើងដោយផ្អែកលើប្រកាសលេខ ធ-៧-០៨-២១១ ប្រក. "ស្តីអំពីអភិបាលកិច្ចគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ដែលតម្រូវឲ្យគ្រឹះស្ថានបង្កើតឡើងនូវគណៈកម្មាធិការហានិភ័យ (មាត្រា៧)។ គណៈកម្មាធិការហានិភ័យ ត្រូវដឹកនាំដោយបុគ្គលដែលមានជំនាញក្នុងផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រងហានិភ័យ។ បុគ្គលនេះត្រូវតែឯករាជ្យពីប្រតិបត្តិការប្រចាំថ្ងៃ។ ជាអប្បបរមា គណៈកម្មាធិការហានិភ័យ ត្រូវទទួលខុសត្រូវសម្រាប់ការតាមដានការអនុវត្តគោលនយោបាយគ្រប់គ្រងហានិភ័យ ដូចបានកំណត់ដោយក្រុមប្រឹក្សាភិបាល (មាត្រា៩)។

ផ្អែកលើខ្លឹមសារកំណត់ក្នុងមាត្រាខាងលើ និងបទប្បញ្ញត្តិពាក់ព័ន្ធ ធនាគារដាក់ឲ្យដំណើរការគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ជាមួយសមាជិកដែលត្រូវបានស្នើដោយគណៈកម្មាធិការអភិបាលកិច្ច ហើយអនុម័តដោយក្រុមប្រឹក្សាភិបាល។

*ទូទៅ*

- តាមដានលើប្រព័ន្ធគ្រប់គ្រងហានិភ័យរបស់ធនាគារ និងត្រួតពិនិត្យរបាយការណ៍ហានិភ័យ ជាមួយកំហុសដែលបានរកឃើញ និងអនុសាសន៍ពីផ្នែកគ្រប់គ្រងប្រតិបត្តិ
- ប្រជុំជាទៀងទាត់ជាមួយនាយកប្រតិបត្តិ នាយកគ្រប់គ្រងហានិភ័យ និងប្រធានអង្គភាពពាក់ព័ន្ធនឹង ជុំវិញកំហុសហានិភ័យដែលបានរកឃើញ និងអនុសាសន៍

- បញ្ជូនសំណើ និងអនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល លើបញ្ហាពាក់ព័ន្ធ ដែលត្រូវការការអនុម័តពីក្រុមប្រឹក្សាភិបាល
- ការវាយតម្លៃប្រចាំឆ្នាំលើ នាយកគ្រប់គ្រងហានិភ័យ និងនាយកដ្ឋានគ្រប់គ្រងហានិភ័យ។

*គោលនយោបាយគ្រប់គ្រងហានិភ័យ*

- ត្រួតពិនិត្យ និងអនុម័តគោលនយោបាយគ្រប់គ្រងហានិភ័យ
- ត្រួតពិនិត្យ និងអនុម័តគោលនយោបាយកំណត់ប្រទេស
- ត្រួតពិនិត្យ និងអនុម័តគោលនយោបាយកំណត់ឥណទានសម្រាប់ប្រតិបត្តិការអន្តរធនាគារ
- ត្រួតពិនិត្យ និងអនុម័តគោលនយោបាយក្របខណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាព
- ត្រួតពិនិត្យ និងអនុម័តគោលនយោបាយតេស្តសុវត្ថិភាពប្រព័ន្ធ (Pen Test)
- ត្រួតពិនិត្យ និងអនុម័តគោលនយោបាយកំណត់កម្រិតឥណទាន (ជាទូទៅ មិនមែនកម្រិតផលិតផល)
- ត្រួតពិនិត្យ និងអនុម័តគោលនយោបាយ ALCO
- ត្រួតពិនិត្យ និងអនុម័តគោលនយោបាយកំណត់តម្លៃសេវាផ្ទេរប្រាក់
- ត្រួតពិនិត្យ និងអនុម័តគោលនយោបាយគ្រប់គ្រងហានិភ័យប្រតិបត្តិការ
- ត្រួតពិនិត្យ និងអនុម័តគោលនយោបាយគ្រប់គ្រងហានិភ័យកេរ្តិ៍ឈ្មោះ
- ត្រួតពិនិត្យ និងអនុម័តគោលនយោបាយសន្តិសុខ IT
- ត្រួតពិនិត្យ និងអនុម័តគោលនយោបាយដោះស្រាយបញ្ហា និងការគ្រប់គ្រងបណ្តឹង
- ត្រួតពិនិត្យ និងអនុម័តគោលនយោបាយគ្រប់គ្រងសន្តិសុខរូបវន្ត
- ត្រួតពិនិត្យ និងអនុម័តគោលនយោបាយផលិតផលថ្មី និងការអភិវឌ្ឍដំណើរការធុរកិច្ច
- ត្រួតពិនិត្យ និងអនុម័តគោលនយោបាយការវិនិយោគ
- ត្រួតពិនិត្យ និងអនុម័តឯកសារពាក់ព័ន្ធផ្សេងៗ។

*មុខងារគ្រប់គ្រងហានិភ័យ*

ពាក់ព័ន្ធនឹងមុខងារគ្រប់គ្រងហានិភ័យ គណៈកម្មាធិការ ត្រូវ៖

- ការអនុម័តរចនាសម្ព័ន្ធមុខងារគ្រប់គ្រងហានិភ័យ ដើម្បីជាអនុសាសន៍ និងព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- ប្រជុំជាមួយនាយកគ្រប់គ្រងហានិភ័យ និងប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យតាមវីដេអូ
- ផ្តល់ការណែនាំចាត់តាំងបេក្ខជនសម្រាប់នាយកគ្រប់គ្រងហានិភ័យ និងប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ
- ត្រួតពិនិត្យ និងផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងហេតុផលដែលជាឫសគល់បង្កឲ្យមានការផ្លាស់ប្តូរ បញ្ចប់តួនាទី និងលាលែងរបស់នាយកគ្រប់គ្រងហានិភ័យ និងប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ។

*ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យតាមដាន និងការកែតម្រូវ*

- ត្រួតពិនិត្យ របាយការណ៍ប្រចាំត្រីមាស ដែលរួមមាន ហានិភ័យទីផ្សារ សន្ទនីយភាព ហានិភ័យឥណទាននិងភាគីប្រឈម ហានិភ័យប្រតិបត្តិការ ហានិភ័យកេរ្តិ៍ឈ្មោះ ដើម្បីជាអនុសាសន៍ ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- ហានិភ័យដែលអាចទទួលយកបាន (Risk Appetite) - ត្រួតពិនិត្យ (ប្រចាំត្រីមាស) និងធ្វើបច្ចុប្បន្នភាព(ប្រចាំឆ្នាំ)
- ការអនុម័តបទប្បញ្ញត្តិប្រព័ន្ធពិន្ទុសមតុល្យដើម្បីជាអនុសាសន៍ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- អនុម័តមូលនិធិប្រចាំឆ្នាំ
- អនុម័តសន្ទនីយភាពនិងផែនការមូលនិធិយថាភាពដើម្បីជាអនុសាសន៍ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- ពិនិត្យការតេស្តសមត្ថភាព (Stress-Tests)

- អនុម័តផែនការតេស្តសុវត្ថិភាពប្រព័ន្ធ (Pen Test) ប្រចាំឆ្នាំ
- ពិភាក្សាប្រចាំត្រីមាសលើ ការតេស្តសុវត្ថិភាពប្រព័ន្ធ (Pen Tests) ដែលត្រូវបានធ្វើឡើងនៅក្នុងអំឡុងរបាយការណ៍និង ស្ថានភាពនៃផែនការសកម្មភាពផ្អែកលើការតេស្តសុវត្ថិភាពប្រព័ន្ធ(Pen Tests) ពីមុន
- អនុម័តផែនការធុរកិច្ចបន្តនិងការសង្គ្រោះពីមហន្តរាយ
- អនុម័តកម្រិតហានិភ័យ(លើកលែងអ្វីដែលពាក់នឹងហានិភ័យឥណទាន) ពីលើអាជ្ញាធរ ALCO ដើម្បីជាអនុសាសន៍ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល។

អ្នកដែលត្រូវបានអញ្ជើញ (លើកលែងប្រធានក្រុមប្រឹក្សាភិបាល) និងអ្នកសង្កេតការណ៍មិនចូលរួមក្នុងការប្រជុំតាមវីដេអូ។

## លទ្ធផលនៃការអនុវត្តការងាររបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

ក្នុងឆ្នាំ ២០២១ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ ប្រារព្ធកិច្ចប្រជុំ ៤ ដែលត្រូវបានធ្វើឡើងរៀងរាល់ត្រីមាស

សកម្មភាពដែលត្រូវបានធ្វើឡើងដោយគណៈកម្មាធិការមានដូចខាងក្រោម៖

- ពិភាក្សាលើប្រូហ្វាលហានិភ័យរបស់ធនាគារ
- ពិភាក្សាលើបច្ចុប្បន្នភាពប្រចាំឆ្នាំនៃ រង្វាស់ហានិភ័យអាចទទួលយកបាន
- ពិភាក្សាលើការអនុវត្តក្របខណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាព
- ពិភាក្សាលើកម្រិតស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណ និង កម្រិតពិសេសចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- អនុម័តលើគោលនយោបាយកំណត់ឥណទានដែលធ្វើបច្ចុប្បន្នភាពរួចសម្រាប់ប្រតិបត្តិការអន្តរធនាគារ និងគោលនយោបាយហានិភ័យទីផ្សារថ្មីរបស់ធនាគារ
- ពិនិត្យប្រូហ្វាលសន្តិសុខព័ត៌មាន និងអនុម័តគោលនយោបាយសន្តិសុខព័ត៌មានរបស់ធនាគារ
- ពិភាក្សាលើការគ្រប់គ្រងនិរន្តភាពអាជីវកម្មរបស់ធនាគារ
- ពិភាក្សាលើរបាយការណ៍តេស្តប្រព័ន្ធសុវត្ថិភាព (Pen Test) និងអនុម័តផែនការតេស្តប្រព័ន្ធសុវត្ថិភាព (Pen Test) ឆ្នាំ២០២២
- វាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំរបស់ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ។

### ១.៤. គណៈកម្មាធិការប្រតិបត្តិតាម

| ល.រ | ឈ្មោះ | តំណែង | ចំនួនសមាសភាពចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|
| ១ | លោក Henri Calvet | ប្រធាន | ៤ | ៤ |
| ២ | លោក Paolo Pizzuto | សមាជិក | ៤ | |
| ៣ | លោក Dominic Jacques | សមាជិក | ៤ | |
| ៤ | លោក Guy Quaden | សមាជិក | ៤ | |

## តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាធិការប្រតិបត្តិតាម

ប្រកាស ធ៧-០៨-០៨៩ប្រក. “ស្តីអំពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម” មាត្រា៣៤ ការគ្រប់គ្រងហានិភ័យ ដែលចែងថាក្រុមប្រឹក្សាភិបាលរបស់ធនាគារត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាពសម្រាប់ការប្រតិបត្តិតាម AML/CFT ជាមួយច្បាប់និងបទប្បញ្ញត្តិតម្រូវ។

ផ្នែកតាមខ្លឹមសារខាងលើនិងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងផ្នែកប្រតិបត្តិតាមធនាគារបានដាក់ឲ្យដំណើរការគណៈកម្មាធិការប្រតិបត្តិតាមជាមួយសមាជិកភាពដែលស្នើឡើងដោយគណៈកម្មាធិការអភិបាលកិច្ចនិងអនុម័តដោយក្រុមប្រឹក្សាភិបាល។

*ទូទៅ*

- សង្កេតតាមដានមុខងារប្រតិបត្តិតាម និងត្រួតពិនិត្យរបាយការណ៍ប្រតិបត្តិតាមជាមួយការរកឃើញកំហុសនិងការផ្តល់អនុសាសន៍ពីផ្នែកគ្រប់គ្រងការប្រតិបត្តិ។
- ប្រជុំជាមួយនាយកប្រតិបត្តិនាយកប្រតិបត្តិតាមនិងប្រធានអង្គភាពពាក់ព័ន្ធជុំវិញការរកឃើញកំហុសប្រតិបត្តិតាមនិងការផ្តល់អនុសាសន៍
- បញ្ជូនសំណើនិងអនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលសម្រាប់បញ្ហានានាដែលត្រូវការការអនុម័តពីក្រុមប្រឹក្សាភិបាល។

*គោលនយោបាយប្រតិបត្តិតាម*

- ត្រួតពិនិត្យនិងអនុម័តគោលនយោបាយគ្រប់គ្រងប្រតិបត្តិតាម
- ត្រួតពិនិត្យនិងអនុម័តក្រមសីលធម៌វិជ្ជាជីវៈ
- ត្រួតពិនិត្យនិងអនុម័តគោលនយោបាយអំណោយ
- ត្រួតពិនិត្យនិងអនុម័តគោលនយោបាយប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ត្រួតពិនិត្យនិងអនុម័តឯកសារពាក់ព័ន្ធផ្សេងៗ។

*ហានិភ័យប្រតិបត្តិតាម*

- ការអនុម័តផែនការសកម្មភាព AML ដើម្បីជាអនុសាសន៍ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- បន្តតាមដានផែនការសកម្មភាព AMLដើម្បីជាអនុសាសន៍ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- ការអនុម័តផែនការសកម្មភាពសវនកម្មប្រតិបត្តិតាមដើម្បីជាអនុសាសន៍ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- ការត្រួតពិនិត្យរបាយការណ៍សវនកម្មប្រតិបត្តិតាមដើម្បីជាអនុសាសន៍ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- បន្តតាមដានផែនការសកម្មភាពលើការកែប្រែកំហុសដែលបានរកឃើញពីសវនកម្មប្រតិបត្តិតាម
- ត្រួតពិនិត្យរបាយការណ៍ហានិភ័យប្រតិបត្តិតាមដើម្បីជាអនុសាសន៍ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- ការទទួលយកអតិថិជនមានហានិភ័យខ្ពស់។

*មុខងារប្រតិបត្តិតាម*

- ត្រួតពិនិត្យអាណត្តិនិងដែនកំណត់នៃមុខងារប្រតិបត្តិតាម
- អនុម័តកញ្ចប់ថវិកាសម្រាប់មុខងារប្រតិបត្តិតាមដើម្បីជាអនុសាសន៍ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- ការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំរបស់នាយក/ប្រធាននាយកដ្ឋានប្រតិបត្តិតាម
- ការត្រួតពិនិត្យប្រចាំឆ្នាំនៃលាភការនាយកប្រតិបត្តិតាម
- ប្រជុំតាមវីដេអូជាមួយនាយកប្រតិបត្តិតាម
- ផ្តល់អនុសាសន៍ចាត់តាំងបេក្ខជនសម្រាប់តួនាទីនាយកប្រតិបត្តិតាម
- រួតពិនិត្យនិងផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងហេតុផលដែលជាឫសគល់បង្កឲ្យមានការផ្លាស់ប្តូរបញ្ចប់តួនាទីនិងលាលែងរបស់នាយក/ប្រធាននាយកដ្ឋានប្រតិបត្តិតាម។

អ្នកដែលត្រូវបានអញ្ជើញ (លើកលែងប្រធានក្រុមប្រឹក្សាភិបាល) និងអ្នកសង្កេតការណ៍មិនចូលរួមក្នុងការប្រជុំតាមវីដេអូ។

## លទ្ធផលនៃការអនុវត្តការងាររបស់គណៈកម្មាធិការប្រតិបត្តិតាម

ក្នុងឆ្នាំ ២០២១ គណៈកម្មាធិការប្រតិបត្តិតាម ប្រារព្ធកិច្ចប្រជុំ ៤ ដែលត្រូវបានធ្វើឡើងរៀងរាល់ត្រីមាស។

សកម្មភាពដែលត្រូវបានធ្វើឡើងដោយគណៈកម្មាធិការមានដូចខាងក្រោម៖

- ពិភាក្សាលើប្រូហ្វាលប្រតិបត្តិតាមរបស់ធនាគារ
- ពិភាក្សា និងអនុម័តគោលនយោបាយការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មដែលត្រូវ បានធ្វើបច្ចុប្បន្នភាព និងគោលនយោបាយនៃការជួញដូរព័ត៌មានផ្ទៃក្នុងរបស់ធនាគារ
- ពិភាក្សាលើរបាយការណ៍ FATCA ឆ្នាំ ២០២១
- ពិភាក្សាការអនុវត្តការងាររបស់នាយកដ្ឋានគ្រប់គ្រងគុណភាពពាក់ព័ន្ធនឹងផ្នែកប្រតិបត្តិតាម
- អនុម័តគោលនយោបាយប្រឆាំងអំពើសូកប៉ាន់ និងប្រឆាំងអំពើពុករលួយដែលបានកែសម្រួល
- ពិភាក្សាលើរបាយការណ៍ហានិភ័យប្រតិបត្តិតាមនិយ័តករ
- វាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំរបស់ទីប្រឹក្សាប្រតិបត្តិតាមរបស់នាយកប្រតិបត្តិ និងប្រធាននាយកដ្ឋានប្រតិបត្តិ

ចន្លោះនេះទុកទំនេរ

## ១.៥. គណៈកម្មាធិការឥណទាន

| ល.រ | ឈ្មោះ | តំណែង | ចំនួនសមាសភាពចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|
| ១ | លោក Christian St-Arnaud | ប្រធាន | ៤ | ៤ |
| ២ | លោក Dominic Jacques | សមាជិក | ៤ | |
| ៣ | លោក Martin Ouellet | សមាជិក | ៤ | |
| ៤ | លោក Henri Calvet | សមាជិក | ៤ | |

ប្រកាសលេខ ធ៧-០៥-០៥៤ប្រក. "ស្តីពីគោលនយោបាយ នីតិវិធី និងសិទ្ធិផ្តល់កម្ចី" ដែលចែងថាគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ត្រូវសរសេរគោលនយោបាយនិងនីតិវិធីដែលអនុម័តដោយថ្នាក់ដឹកនាំនិង/ឬក្រុមប្រឹក្សាភិបាលនិងកំណត់កម្រិតសិទ្ធិផ្តល់កម្ចីរបស់មន្ត្រីនិង/ឬគណៈកម្មាធិការឥណទាននិងក្រុមប្រឹក្សាភិបាល(មាត្រា២)។

ផ្អែកតាមខ្លឹមសារខាងលើនិងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀតធនាគារបានដាក់ឲ្យដំណើរការគណៈកម្មាធិការឥណទានជាមួយសមាជិកភាពដែលត្រូវបានស្នើឡើងដោយគណៈកម្មាធិការអភិបាលកិច្ចនិងអនុម័តដោយក្រុមប្រឹក្សាភិបាល។

### *ទូទៅ*

- សង្កេតតាមដានសកម្មភាពឥណទានរបស់ធនាគារផ្អែកតាមយុទ្ធសាស្រ្តឥណទាននិងគោលនយោបាយ
- ប្រជុំជាមួយនាយកប្រតិបត្តិនិងនាយកឥណទានដើម្បីវាយតម្លៃពីប្រសិទ្ធភាពយុទ្ធសាស្រ្តធុរកិច្ចនិងនយោបាយឥណទានរបស់ធនាគារ
- បញ្ជូនសំណើនិងអនុសាសន៍លើបញ្ហានានាដែលត្រូវការការអនុម័តពីក្រុមប្រឹក្សាភិបាល។

### *នយោបាយឥណទាន*

- អនុម័តនយោបាយឥណទាននិងចាត់តាំងបុគ្គលមានសិទ្ធិដែលត្រូវបានអនុម័តដើម្បីគ្រប់គ្រងគណៈកម្មាធិការឥណទានសម្រាប់ជាអនុសាសន៍ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- អនុម័តនយោបាយគ្រប់គ្រងទ្រព្យតម្កល់សម្រាប់សម្រាប់ជាអនុសាសន៍ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល
- អនុម័តនយោបាយដោះស្រាយបំណុលនិងការប្រមូលសម្រាប់ជាអនុសាសន៍ឬព័ត៌មានដល់ក្រុមប្រឹក្សាភិបាល។

### *ផលបត្រឥណទាន*

- ត្រួតពិនិត្យទំនោរផលបត្រឥណទាននិងការអនុវត្ត
- ត្រួតពិនិត្យផលបត្រ NPL
- ត្រួតពិនិត្យការផ្តល់ឥណទានរូបវន្តបុគ្គល
- ផ្តល់អនុសាសន៍ការប្រើប្រាស់ឧបករណ៍សម្រាប់ត្រួតពិនិត្យនិងវាស់វែងហានិភ័យនៃឥណទាន។

### *ការអនុម័តឥណទាន*

- ការអនុម័តឥណទានតាមសិទ្ធិអនុញ្ញាតត្រូវបានកំណត់ក្នុងគោលនយោបាយឥណទាន។

### *មុខងារឥណទាន*

- ធ្វើការប្រជុំជាមួយនាយកឥណទានតាមវីដេអូ
- ផ្តល់អនុសាសន៍ចាត់តាំងបេក្ខជនសម្រាប់តួនាទីនាយកឥណទាន។

អ្នកដែលត្រូវបានអញ្ជើញ (លើកលែងប្រធានក្រុមប្រឹក្សាភិបាល) និងអ្នកសង្កេតការណ៍មិនចូលរួមក្នុងការប្រជុំតាមវីដេអូ។

## លទ្ធផលនៃការអនុវត្តការងាររបស់គណៈកម្មាធិការឥណទាន

ក្នុងឆ្នាំ ២០២១ គណៈកម្មាធិការឥណទាន ប្រារព្ធកិច្ចប្រជុំ ៤ ដែលត្រូវបានធ្វើឡើងរៀងរាល់ត្រីមាស។

សកម្មភាពដែលត្រូវបានធ្វើឡើងដោយគណៈកម្មាធិការមានដូចខាងក្រោម៖

- ពិភាក្សាលើផលបត្រឥណទានរបស់ធនាគារ
- ពិភាក្សាលើតម្រូវការអនុវត្តធៀបនឹងតម្រូវការនិយ័តករសម្រាប់ឥណទានជាប្រាក់រៀល
- ពិភាក្សាលើចំនួនខាតបង់ឥណទានរំពឹងទុកសម្រាប់ឥណទានរៀបចំឡើងវិញបណ្ដាលមកពីជំងឺកូវីដ
- កែសម្រួលវិធីសាស្ត្រចែកថ្នាក់ហានិភ័យឥណទាន
- ពិភាក្សាលើយុទ្ធសាស្ត្រកម្ចីដល់សហគ្រាសធុនតូចនិងមធ្យម
- អនុម័តលើគោលនយោបាយឥណទានដែលបានកែសម្រួលរបស់ធនាគារ

### ២. ការផ្លាស់ប្ដូរសមាជិកគណៈកម្មាធិការ

| ល.រ | គណៈកម្មាធិការ | ឈ្មោះ | មូលហេតុ |
|---|---|---|---|
| ១ | សវនកម្ម | គ្មាន | គ្មាន |
| ២ | អភិបាលកិច្ច | គ្មាន | គ្មាន |
| ៣ | គ្រប់គ្រងហានិភ័យ | គ្មាន | គ្មាន |
| ៤ | ប្រតិបត្តិតាម | គ្មាន | គ្មាន |
| ៥ | ឥណទាន | គ្មាន | គ្មាន |

## គ. លាភការ ឬប្រាក់បំណាច់

### ១. គោលនយោបាយសង្ខេបស្ដីពីលាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

លាភការនិងប្រាក់បំណាច់ស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់គណៈកម្មាធិការអភិបាលកិច្ចនិងក្រុមប្រឹក្សាភិបាល។

### ២. បុគ្គលទទួលបានលាភការ ឬប្រាក់បំណាច់

ដោយសារតែការរក្សាការសម្ងាត់ផ្ទៃក្នុង ធនាគារ ABA នឹងបង្ហាញតែលាភការ និងប្រាក់បំណាច់របស់ភាគហ៊ុនិក អភិបាល និងគណៈគ្រប់គ្រងសំខាន់ៗ ជាសរុប ពីព្រោះតួលេខត្រូវបានអនុម័ត និងស្របជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មរួចដោយសវនករឯករាជ្យនៅក្នុងកំណត់សម្គាល់៣១(យ)។

| ល.រ | បុគ្គលទទួលបានលាភការ ឬប្រាក់បំណាច់ | ចំនួនលាភការ ឬប្រាក់បំណាច់ |
|---|---|---|
| ១ | អភិបាល និងថ្នាក់ដឹកនាំសំខាន់ៗ | ២៤.០០៣.៧៤២ ដុល្លារអាមេរិក |

### ឃ.ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល អភិបាលនីមួយៗ គណៈកម្មាធិការ និងនាយកប្រតិបត្តិ

| ល.រ | បរិយាយ | ដំណើរការនៃការវាយតម្លៃ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|---|
| ១ | ក្រុមប្រឹក្សាភិបាល | ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាលត្រូវបានវាយតម្លៃដោយភាគហ៊ុនិក | ▪ សមាសភាពក្រុមប្រឹក្សាភិបាល<br>▪ ការយល់ដឹងពីធនាគារ និងធុរកិច្ចធនាគារ<br>▪ ការចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល |
| ២ | អភិបាល | ការអនុវត្តការងាររបស់អភិបាលនៃក្រុមប្រឹក្សាភិបាលត្រូវបានវាយតម្លៃដោយភាគហ៊ុនិក | ▪ សមត្ថភាពស្នូល<br>▪ ការយល់ដឹងពីធនាគារ និងធុរកិច្ចធនាគារ<br>▪ ការចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងកិច្ចប្រជុំគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល |
| ៣ | គណៈកម្មាធិការ | ការអនុវត្តការងាររបស់គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាលត្រូវបានវាយតម្លៃដោយប្រធានក្រុមប្រឹក្សាភិបាល | ▪ សិទ្ធិរបស់គណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល<br>▪ គុណភាពការអនុវត្តការងារ |
| ៤ | នាយកប្រតិបត្តិ | ការអនុវត្តការងាររបស់នាយកប្រតិបត្តិត្រូវបានវាយតម្លៃដោយគណៈកម្មាធិការអភិបាលកិច្ចនៃក្រុមប្រឹក្សាភិបាលដោយមានវត្តមានរបស់នាយកប្រតិបត្តិ។ បន្ទាប់មក ប្រធានគណៈកម្មាធិការអភិបាលកិច្ចប្រគល់ការវាយតម្លៃជូនក្រុមប្រឹក្សាភិបាលអនុម័ត។ | ▪ សូចនាករអនុវត្តការងារ (KPIs)<br>▪ សមត្ថភាពស្នូល |

### ង. ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

ក្នុងឆ្នាំ ២០២១ មន្ត្រីជាន់ខ្ពស់របស់ធនាគារបានចូលរួមក្នុងការបណ្តុះបណ្តាលពី និយ័តករមូលបត្រកម្ពុជា ដូចខាងក្រោម៖

| ឈ្មោះ | មុខតំណែង | វគ្គសិក្សា |
|---|---|---|
| លោក Zhiger Atchabarov | នាយកប្រតិបត្តិការអន្តរជាតិ | ▪ កម្មវិធីសិក្ខាសាលាលើគោលការណ៍ណែនាំស្តីពី"ការអនុវត្តក្របខណ្ឌគតិយុត្តពាក់ព័ន្ធនឹងការបោះផ្សាយសញ្ញាបណ្ណជាពហុរូបិយវត្ថុរបស់អាស៊ានបូកបី(AMBIF)" |
| កញ្ញា ឡាយ ជីវម៉ី | ប្រធានផ្នែកទទួលបន្ទុកផ្តល់ព័ត៌មាន | ▪ កម្មវិធីសិក្ខាសាលាដើម្បីបញ្ជ្រាបការយល់ដឹងពាក់ព័ន្ធនឹងសារាចរណែនាំស្តីពី"ការប្រើប្រាស់ភាសា និងរូបិយប័ណ្ណ ក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ" |

# ផ្នែកទី ៣

## ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

## ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

យើងមានការទទួលខុសត្រូវក្នុងការការពារសុចរិតភាព និងភាពជឿជាក់ដើម្បីការពារផលប្រយោជន៍របស់អតិថិជនដាក់ប្រាក់បញ្ញើ និងវិនិយោគិន និងទំនុកចិត្តលើអាជីវកម្មរបស់ធនាគារ។ នៅក្នុងធនាគារ ABA វាជាការទទួលខុសត្រូវរបស់អ្នកគ្រប់គ្នាក្នុងការធានាថា ធនាគារត្រូវបានគ្រប់គ្រងប្រកបដោយភាពត្រឹមត្រូវ និងប្រកបដោយវិជ្ជាជីវៈ។

ដូច្នេះ សមាជិកគ្រប់រូបទាំងអស់របស់ធនាគារ ABA ត្រូវតែអនុវត្តការងាររបស់ពួកគេដោយសុចរិតភាព និងសេចក្តីគោរពបំផុត ក៏ដូចជាគុណតម្លៃសុជីវធម៌ខ្ពស់បំផុត និងការប្រតិបត្តិតាមច្បាប់។ ធនាគាររំពឹងដូចគ្នានេះពីភាគីទាំងអស់ដែលខ្លួនមានទំនាក់ទំនងជាមួយ។

ក្រមប្រតិបត្តិ និងក្រមសីលធម៌អាជីវកម្ម "ក្រមប្រតិបត្តិ" ត្រូវបានចងក្រងជាឯកសារដើម្បីដាក់ចេញជាបទប្បញ្ញត្តិ និងបទដ្ឋានអំពីរបៀបដែលយើងទាំងអស់គ្នាធ្វើការដើម្បីអភិវឌ្ឍធនាគារ ABA និងផ្តល់សេវាកម្មដល់អតិថិជនរបស់យើង ពោលគឺរបៀបដែលយើងការពារគុណតម្លៃរបស់ធនាគារ ABA និងអត្ថប្រយោជន៍របស់ភាគទុនិករបស់យើង និងរបៀបដែលយើងប្រព្រឹត្តទៅលើបុគ្គលិក និងសហគមន៍នៅកន្លែងដែលយើងធ្វើអាជីវកម្ម។

ក្រមប្រតិបត្តិនេះបានកំណត់នូវបទប្បញ្ញត្តិ និងវិធានកម្រិតខ្ពស់សម្រាប់ធ្វើអាជីវកម្ម និងក្រមសីលធម៌ ដែលត្រូវបានអនុវត្តសម្រាប់គ្រប់គ្នានៅក្នុងធនាគារ ABA រួមទាំងក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិក។ ក្រមប្រតិបត្តិនេះក៏អនុវត្តផងដែរចំពោះបុគ្គលិកក្នុងរយៈពេលសាកល្បងការងារ អ្នកហាត់ការ និងបុគ្គលិករបស់ភាគីទីបីដែលផ្តល់សេវាកម្មហិរញ្ញវត្ថុ និងសេវាកម្មផ្សេងៗ ដោយផ្អែកលើភាពជាដៃគូពីខាងក្រៅជាមួយធនាគារ។

ក្រមប្រតិបត្តិរបស់ធនាគារ ABA បានបញ្ជាក់ពីគោលការណ៍ប្រតិបត្តិទាំង៦ របស់យើង៖

- យើងសម្រេចគោលដៅដោយប្រកាន់ខ្ជាប់នូវគុណតម្លៃសាជីវកម្មរបស់យើង
- យើងទាំងអស់គ្នាបង្កើតគ្រួសារ ABA ហើយប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកដោយយុត្តិធម៌
- យើងមានបំណងផ្តល់អត្ថប្រយោជន៍ដល់អតិថិជនរបស់យើង
- យើងការពារ និងបង្កើនតម្លៃរបស់ភាគទុនិករបស់យើង
- យើងចូលរួមចំណែកក្នុងជោគវាសនារបស់ប្រទេសជាតិ និង
- ការរំលឹកលើការសួរសំណួរ និងរាយការណ៍។

### យើងសម្រេចគោលដៅដោយប្រកាន់ខ្ជាប់នូវគុណតម្លៃសាជីវកម្មរបស់យើង

**ចក្ខុវិស័យរបស់យើង៖** ដើម្បីក្លាយជាធនាគារលំដាប់លេខមួយប្រចាំប្រទេស លើផ្នែកផ្គត់ផ្គង់សេវាកម្មធនាគារគួរជាទីទុកចិត្ត ងាយស្រួលប្រើប្រាស់ ប្រកបដោយបច្ចេកវិទ្យាទំនើបបំផុត និងងាយស្រួលក្នុងការទទួលបាន។

**បេសកកម្មរបស់យើង៖** ដើម្បីជួយដល់ប្រទេសកម្ពុជា ធុរៈជនកម្ពុជា និងប្រជាជនកម្ពុជានៅក្នុងការកសាងអនាគតកាន់តែទូលំទូលាយ និងត្រចះត្រចង់ តាមរយៈការផ្តល់សេវាធនាគារប្រកបដោយជំនាញវិជ្ជាជីវៈខ្ពស់ នឹងបច្ចេកវិទ្យាទំនើបបំផុតក្នុងផ្នែកធនាគារសម្រាប់អ្នកទាំងអស់គ្នា។

### គុណតម្លៃរបស់យើង៖

*សុច្ចរិតភាព និងសេចក្តីគោរព* - នៅធនាគារ ABA យើងចាត់ទុកចំណុចនេះជាការទទួលខុសត្រូវខ្ពស់ របស់ធនាគារដែលត្រូវបម្រើសេវាជូនរាល់អតិថិជនប្រកបដោយភាពសុច្ចរិត និងសេចក្តីគោរព។

*ទំនុកចិត្ត និងភាពជាដៃគូ* - នៅធនាគារ ABA យើងនៅទីនេះដើម្បីជួយសម្រួល និងជាជំនួយការរបស់លោកអ្នក។ យើងខិតខំធ្វើឲ្យខ្លួនក្លាយជាដៃគូដ៏ល្អដែលអតិថិជនរបស់យើងអាចជឿទុកចិត្ត។

*គុណភាពនៃសេវាកម្ម* - នៅធនាគារ ABA យើងខិតខំស្វែងរកដំណោះស្រាយដើម្បីឆ្លើយតបចំពោះរាល់តម្រូវការសេវាធនាគារទាំងអស់។ យើងមានបំណងផ្តល់សេវាកម្មធនាគារប្រកបដោយទំនុកចិត្ត និងមានបច្ចេកវិទ្យាទំនើបបំផុតសម្រាប់អតិថិជនទាំងអស់របស់យើង ពោលគឺក្នុងតួនាទីជាជំនួយការគ្រប់គ្រងគណនីផ្ទាល់ខ្លួន ឬគណនីអាជីវកម្មរបស់លោកអ្នក។

*ការចូលរួមចំណែក* - នៅធនាគារ ABA យើងមានបំណងចូលរួមចំណែកធ្វើឲ្យកាន់តែប្រសើរសម្រាប់ប្រទេសកម្ពុជា។ យើងចង់ដើរតួនាទីដែលផ្តល់សារប្រយោជន៍សម្រាប់ការរស់នៅរបស់អតិថិជនយើងក៏ដូចជាសម្រាប់អនាគតរបស់ប្រទេសទាំងមូលផងដែរ។

*និរន្តរភាព និងការរីកចម្រើន* - នៅធនាគារ ABA យើងតែងតែគិតគូរអំពីអនាគតរបស់ធនាគារយើង និងប្រជាជនកម្ពុជា ព្រមទាំងប្រទេសកម្ពុជាផងដែរ។ យើងសូមបង្ហាញនូវការប្តេជ្ញាចិត្តដ៏មោះមុតដូចគ្នាចំពោះបុគ្គលិករបស់យើងក៏ដូចជាអតិថិជនរបស់យើងផងដែរ។ នេះគឺជាវិធីសាស្ត្រមួយ ដែលអាចឲ្យយើងធានាបាននូវការរីកចម្រើនប្រកបដោយនិរន្តរភាពរបស់ធនាគារ។

*ក្រមសីលធម៌ និងសុជីវធម៌* - នៅធនាគារ ABA យើងមានការយកចិត្តទុកដាក់ចំពោះការទទួលខុសត្រូវផ្នែកសង្គមរបស់យើង។ យើងនឹងអនុវត្តស្តង់ដារក្រមសីលធម៌ខ្ពស់ និងមានសុជីវធម៌រវាងគ្នានឹងគ្នា ព្រមទាំងអ្វីគ្រប់យ៉ាងដែលយើងកំពុងអនុវត្តពេលគឺទាំងនៅក្នុង និងក្រៅធនាគារ។

ទាំងនេះគឺជាគោលការណ៍ដែលបង្កើតឡើងជាមូលដ្ឋានគ្រឹះសម្រាប់ការទំនាក់ទំនងប្រចាំថ្ងៃ ពោលគឺជាមួយអតិថិជន និងសហគមន៍ដែលយើងកំពុងផ្តល់សេវាជូន ក៏ដូចជា ជាមួយបុគ្គលិករបស់យើងផងដែរ។

## យើងទាំងអស់គ្នាបង្កើតគ្រួសារ ABA ហើយប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកដោយយុត្តិធម៌

**ការជ្រើសរើសបុគ្គលិក និង ការជ្រើសរើស៖** ធនាគារ ABA ប្តេជ្ញាចិត្តជ្រើសរើសបុគ្គលិកដែល មានគុណសម្បត្តិស័ក្តិសម និងមានបទពិសោធន៍ និងអ្នកដែលមានសមត្ថភាព និងគុណភាពសមស្របដើម្បី បំពេញ តួនាទី របស់ខ្លួននៅក្នុងក្រុម។

**សេចក្តីគោរព និងការមិនរើសអើងនៅក្នុងឱកាសការងារ៖** យើងផ្តល់តម្លៃដល់ភាពចម្រុះនៅក្នុងកម្លាំងពលកម្ម របស់យើង ក៏ដូចជានៅក្នុងចំណោមអតិថិជន អ្នកផ្គត់ផ្គង់ និងអ្នកផ្សេងទៀត។ យើងផ្តល់ឱកាសការងារស្មើៗ គ្នាសម្រាប់បេក្ខជន និងបុគ្គលិកទាំងអស់។ យើងមិនរើសអើងលើមូលដ្ឋានជាតិសាសន៍ ពណ៌សម្បុរ សាសនា ភេទ ប្រទេសកំណើត ពូជពង្ស អាយុ ស្ថានភាពគ្រួសារ ឬលក្ខណៈផ្សេងទៀតណាមួយ ដែលត្រូវបានការពារដោយច្បាប់ និងបទប្បញ្ញត្តិរបស់កម្ពុជាឡើយ។

**ការប្រឆាំងការបៀតបៀន៖** យើងប្តេជ្ញាផ្តល់កន្លែងការងារដោយគ្មានការបៀតបៀនដោយផ្អែកលើលក្ខណៈផ្ទាល់ខ្លួន។

**ការជួញដូរមនុស្ស ពលកម្មកុមារ និងពលកម្មដោយបង្ខំ៖** យើងមិនអត់ឱនឡើយចំពោះការអនុវត្តការងារ ដោយបង្ខំ ឬការជួញដូរមនុស្ស។ ធនាគារ ABA មិនអនុញ្ញាតិឱ្យមានការប្រព្រឹត្តអំពើឃោរឃៅ ឬអមនុស្សធម៌ឡើយ រួមទាំងការដាក់ទណ្ឌកម្មលើរាងកាយ ឬការគំរាមកំហែងនៃការដាក់ទោសទណ្ឌផ្លូវចិត្តផងដែរ។ យើងនឹងមិនជួល នរណាម្នាក់ដែលមានអាយុក្រោម 18 ឆ្នាំនៅក្នុងមុខតំណែងណាមួយឡើយ។

**សុខភាព និងសុវត្ថិភាព៖** ធនាគារ ABA ប្តេជ្ញាយ៉ាងហោចណាស់អនុវត្តតាមតម្រូវការអប្បបរមាដែលបង្កើតឡើង ដោយច្បាប់ការងាររបស់ប្រទេសកម្ពុជា និងស្ថាប័នបង្កើតបទដ្ឋានអន្តរជាតិជាធរមាន (ឧ. ILO)។ យើងផ្តល់បរិយាកាសការងារប្រកបដោយផាសុខភាពជាមួយនឹងឧបករណ៍បច្ចេកវិទ្យាទំនើបៗសម្រាប់បុគ្គលិកនៅគ្រប់កម្រិត។

**ការប្រាស្រ័យទាក់ទងដោយបើកចំហ និងស្មោះត្រង់៖** នៅក្នុងធនាគារ ABA យើងផ្តល់តម្លៃដល់លំហូរគំនិត យោបល់ សំណួរ និងកង្វល់ផ្សេងៗ ដោយសេរី។ យើងជំរុញទឹកចិត្តដល់បុគ្គលិកឱ្យលើកឡើងពីបញ្ហាទាក់ទងនឹងការងារគំនិតផ្តួចផ្តើម ឬកង្វល់ផ្សេងៗ តាមរយៈដំណើរការដែលបានបង្កើតឡើងនៅពេលដែលមានបញ្ហា ឬការ ព្រួយបារម្ភកើតឡើង។

**ការផ្គត់ផ្គង់ហិរញ្ញវត្ថុ និងឥណទានសម្រាប់បុគ្គលិករបស់យើង៖** ធនាគារ ABA មានគោលបំណងបើកប្រាក់ឈ្នួលសមរម្យដល់បុគ្គលិករបស់យើង ដែលជាទូទៅមានប្រាក់បៀវត្សរ៍ថេរ និងប្រាក់រង្វាន់ការងារប្រចាំឆ្នាំ ឬប្រចាំត្រីមាស។ ប៉ុន្តែក្នុងករណីមានភាពអាសន្ន បុគ្គលិករបស់យើងអាចដាក់ពាក្យសុំទៅនាយកដ្ឋានហិរញ្ញវត្ថុដើម្បីស្នើសុំប្រាក់បុរេប្រទាន សម្រាប់ការប្រើប្រាស់បន្ទាន់ផ្ទាល់ខ្លួន ឬសម្រាប់គ្រួសារ។ ភ្នាក់ងារហិរញ្ញវត្ថុអាចយល់ព្រមលើប្រភេទប្រាក់បុរេប្រទាននេះបាន លុះត្រាតែបុគ្គលិកនោះធ្វើការនៅធនាគារ ក្នុងរយៈពេលមិនតិចជាង 3ខែ មិនមានការព្រមានណាមួយ ហើយអាចទូទាត់សងប្រាក់បុរេប្រទានវិញពីប្រាក់បៀវត្សរ៍ ក្នុងរយៈពេល 3ខែ ខាងមុខ។

**តំណាងបុគ្គលិក៖** យោងទៅតាមច្បាប់ការងាររបស់កម្ពុជា បុគ្គលិករបស់យើងមានសិទ្ធិបង្កើតស្ថាប័នវិជ្ជាជីវៈ ឬតែងតាំងអ្នកតំណាងសម្រាប់គោលបំណងផ្តាច់មុខក្នុងការសិក្សា និងលើកកម្ពស់អត្ថប្រយោជន៍របស់បុគ្គលិក ការពារ សិទ្ធិរបស់ពួកគេ និងផ្តល់យោបល់អោយថ្នាក់គ្រប់គ្រងរបស់ធនាគារ។

**ចំណេះដឹង និងការងារជាក្រុម៖** យើងលើកទឹកចិត្តដល់បុគ្គលិករបស់យើងឱ្យបន្តអប់រំខ្លួនឯង និងចែករំលែកចំណេះដឹងនេះជាមួយអ្នកដទៃនៅពេលយើងកំពុងរួមគ្នាឆ្ពោះទៅរកគោលដៅរួម។ ដូច្នេះការចែករំលែកចំណេះដឹង ការបង្វឹក និងការប្រៀនប្រដៅ សិក្ខាសាលា និងការបណ្តុះបណ្តាលគឺជាផ្នែកនៃដំណើរការអប់រំជាបន្ត។

## យើងមានគោលដៅផ្តល់អត្ថប្រយោជន៍ដល់អតិថិជនរបស់យើង

**ផ្តល់អត្ថប្រយោជន៍ដល់អតិថិជន៖** ជោគជ័យរបស់យើងគឺអាស្រ័យលើក្រុមការងារ និងអតិថិជនរបស់យើង។ យើងឃើញថាបេសកកម្មរបស់យើងបានសម្រេច នៅពេលអតិថិជនរបស់យើងទទួលបានអត្ថប្រយោជន៍ពីផលិតផល និងសេវាកម្មរបស់យើង។ នោះហើយជាមូលហេតុដែលក្នុងអំឡុងពេលធ្វើអាជីវកម្មការផ្តោតជាសំខាន់របស់យើង គឺការផ្តល់អត្ថប្រយោជន៍ដល់អតិថិជន។

**ក្រមវិន័យ និងគុណភាព៖** អាជីវកម្មរបស់យើងគឺផ្អែកលើទំនាក់ទំនងរឹងមាំនៃការគោរពគ្នាទៅវិញទៅមក និងការជឿទុកចិត្តគ្នាជាមួយអតិថិជន អ្នកផ្គត់ផ្គង់ និងដៃគូរបស់យើង។ ដើម្បីថែរក្សាទំនាក់ទំនងដ៏រឹងមាំទាំងនេះ យើងប្រព្រឹត្តចំពោះអ្នកទាំងអស់គ្នាដែលយើងមានទំនាក់ទំនងជាមួយ ដូចដែលយើងរំពឹងថាអ្នកទាំងនោះនឹងប្រព្រឹត្តចំពោះយើងវិញដូចគ្នាដោយភាពយុត្តិធម៌ សុចរិតភាព និងសេចក្តីគោរព។

**អនុវត្តតាមលិខិត និងស្មារតីច្បាប់៖** ក្នុងនាមជាធនាគារយើងត្រូវតែគោរពតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក ក៏ដូចជាឧត្តមានុវត្តន៍ជាអន្តរជាតិនៅក្នុងអាជីវកម្មរបស់យើង។ យើងទទួលខុសត្រូវក្នុងការដឹងឮ និងអនុវត្តតាម ច្បាប់ ឬបទប្បញ្ញត្តិទាំងអស់ជាធរមាន។

**ភាពស្របច្បាប់ និងសមត្ថភាព៖** យើងផ្តល់ជូនអតិថិជនរបស់យើងនូវផលិតផល និងសេវាកម្មតែប៉ុណ្ណោះនៅពេល ដែលយើងមានអាជ្ញាប័ណ្ណស្របច្បាប់ និងជំនាញគ្រប់គ្រាន់ដែលពាក់ព័ន្ធ រួមទាំងបុគ្គលិកដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ បរិវេណ និងបរិក្ខារត្រឹមត្រូវ មុខងារគាំទ្រចាំបាច់ និងសមត្ថភាពក្នុងការត្រួតពិនិត្យតាមដាន និងគ្រប់គ្រងហានិភ័យដែលពាក់ព័ន្ធ។

**ការទំនាក់ទំនង និងភាសា៖** យើងមានបំណងដើម្បីធ្វើឱ្យឯកសារទាំងអស់ដែលអាចធ្វើបានរួមទាំងការផ្សព្វផ្សាយ ពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងនានានៅក្នុងប្រតិបត្តិការរបស់យើងទាំងពីរភាសា i) ភាសាអង់គ្លេស និង ii) ភាសាខ្មែរ ដើម្បីចៀសវាង និងកាត់បន្ថយឧបសគ្គភាសាសម្រាប់អតិថិជនរបស់យើង។

**មតិយោបល់របស់អតិថិជន៖** រាល់ពាក្យត្អូញត្អែររបស់អតិថិជនទាំងអស់ត្រូវបានដាក់ នៅក្នុងការស៊ើបអង្កេត ផ្ទៃក្នុងយ៉ាងហ្មត់ចត់ និង តាមរយៈវិធានការយ៉ាងសមស្របដើម្បីលុបបំបាត់គុណវិបត្តិដែលលេចធ្លាយ ដោយការកែលម្អសេវាអតិថិជន និងនាំមកនូវការពេញចិត្តខ្ពស់ពីអតិថិជន។

**គោលនយោបាយប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម៖** ធនាគារ ABA ប្តេជ្ញាចូលរួមក្នុង កិច្ចខិតខំ ប្រឹងប្រែងជាអន្តរជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT)។ ដើម្បីអនុលោមតាមច្បាប់ក្នុងប្រទេស និងច្បាប់អន្តរជាតិ ធនាគារ ABA បានបង្កើត និងអនុវត្តគោលនយោបាយ ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដោយមាននីតិវិធីរៀងៗខ្លួន និងយន្តការត្រួតពិនិត្យ។

**អាជីវកម្មដែលត្រូវបានហាមឃាត់៖** ស្របតាមគុណតម្លៃ ចក្ខុវិស័យ និងបេសកកម្មរបស់ធនាគារ ABA យើង មានកម្លាំងថាមពលសម្រាប់កំណើនប្រកបដោយនិរន្តរភាពមួយដោយហេតុថាការការពារសង្គម និងបរិស្ថានគឺជា ផ្នែកដ៏សំខាន់ក្នុងការអភិវឌ្ឍអាជីវកម្មរបស់យើង។

**ឯកជនភាព និង ការសម្ងាត់៖** យើងប្តេជ្ញាការពារការរំពឹងទុក អំពីឯកជនភាពរបស់មនុស្សគ្រប់រូបដែលយើង ធ្វើអាជីវកម្មជាមួយរួមមានអតិថិជនរបស់យើង អ្នកផ្គត់ផ្គង់ និងដៃគូ ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីធនាគារ។ យើងជឿជាក់ថាការយកចិត្តទុកដាក់ប្រកបដោយទំនួលខុសត្រូវចំពោះព័ត៌មានបុគ្គល ជួយថែរក្សានូវទំនុកចិត្ត មកលើធនាគារ ABA និងប្រព័ន្ធហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាជារួម។

**ការប្រកួតប្រជែងស្មើភាពនិងការប្រឆាំងការប្រកួតប្រជែងផ្តាច់មុខ៖** បទប្បញ្ញត្តិស្តីពីការប្រកួតប្រជែងគ្រប់គ្រងលើអាកប្បកិរិយារបស់ក្រុមហ៊ុននៅក្នុងទីផ្សារ។ នៅគ្រប់សាខាទាំងអស់ដែលយើងធ្វើអាជីវកម្ម យើងប្តេជ្ញាថា នឹងប្រកួតប្រជែងឱ្យមានប្រសិទ្ធិភាពដើម្បីអ្នកផ្គត់ផ្គង់ និងអតិថិជនប៉ុន្តែប្រកួតប្រជែងដោយស្មើភាព។

**ការប្រឆាំងសំណូក & ការប្រឆាំងអំពើពុករលួយ៖** យើងនឹងមិនផ្តល់ជូន ឬទទួលយកសំណូក ឬប្រាក់ទឹកតែ ហើយនឹងមិនចូលរួម ឬសម្របសម្រួលសកម្មភាពអំពើពុករលួយណាមួយឡើយ។ ដោយសារសំណូក និងអំពើ ពុករលួយ គឺជាការគំរាមកំហែង

យ៉ាងធ្ងន់ធ្ងរដល់អភិបាលកិច្ចល្អការអនុវត្តអាជីវកម្មស្មើភាព និងការអភិវឌ្ឍន៍ ប្រកបដោយនិរន្តរភាព អ្នកគ្រប់គ្រងរបស់ធនាគារ ABA បានប្ដេជ្ញាចិត្ត ចូលរួមចំណែកក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងសំណូកនៅក្នុងវិស័យសាធារណៈ និងឯកជន។

## យើងការពារ និងបង្កើនតម្លៃរបស់ភាគទុនិករបស់យើង

**ប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីជាផលប្រយោជន៍ដល់ធនាគារ ABA៖** យើងនឹងខិតខំប្រឹងប្រែងឱ្យអស់ពី សមត្ថភាព ដើម្បីរក្សា និងបង្កើនតម្លៃរបស់ភាគទុនិករបស់ធនាគារ ABA។ នេះទាមទារឱ្យមានការប្រតិបត្តិដែលល្អ ឥតខ្ចោះដើម្បីជាផលប្រយោជន៍ដល់ធនាគារ ABA ដោយគិតគូរដល់ផលប្រយោជន៍របស់អតិថិជន និងប្រទេស របស់យើងដូចដែលមានចែងនៅក្នុងក្រមប្រតិបត្តិនេះ។

**សិទ្ធិប្រើប្រាស់ធនធានរបស់ធនាគារ ABA៖** យើងចំនាយធនធានយ៉ាងសន្សឹកសន្សាប់ដើម្បីរក្សា និងអភិវឌ្ឍអាជីវកម្ម របស់ធនាគារ ABA ។ ធនធានរបស់យើងរួមមានមធ្យោបាយ គ្រឿងបរិក្ខារ កុំព្យូទ័រ និងប្រព័ន្ធទំនាក់ទំនង កម្មសិទ្ធិបញ្ញា ហិរញ្ញវត្ថុ និងទ្រព្យសកម្មផ្សេងៗទៀត។

**ការថែរក្សាសុវត្ថិភាពព័ត៌មាន៖** ព័ត៌មានកម្មសិទ្ធិគឺជាទ្រព្យដ៏មានតម្លៃរបស់ធនាគារ និងរួមបញ្ចូលទាំងការទំនាក់ ទំនងខាងក្នុង និងខាងក្រៅ។ ព័ត៌មានឌីជីថលដែលមាននៅលើកុំព្យូទ័រយួរដៃ ឧបករណ៍ អេឡិកត្រូនិកចល័ត កុំព្យូទ័រលើតុ ម៉ាស៊ីន Sever ឧបករណ៍បម្រុងទិន្នន័យ និងឧបករណ៍ផ្ទុកចល័ត នឹងឯកសាររឹង ការពិភាក្សាដោយផ្ទាល់មាត់ នឹងទំនាក់ទំនងតាមរយៈបណ្ដាញផ្សព្វផ្សាយសង្គមនានា។

**ការការពារតម្លៃកេរ្ដិ៍ឈ្មោះអាជីវកម្ម (ប្រេន) ធនាគារABA៖** ក្នុងចំណោមទ្រព្យដ៏មានតម្លៃបំផុតរបស់យើងគឺឈ្មោះ ម៉ាករបស់ធនាគារ ABA ។ ដើម្បីការពារគុណតម្លៃ និងការទទួលស្គាល់នូវ ឈ្មោះម៉ាករបស់យើង យើងបានបង្កើតគោលការណ៍ណែនាំដែលបញ្ជាក់ថា តើរបៀបណា និងនៅពេលណាដែលអាចប្រើប្រាស់ឈ្មោះម៉ាក និងលក្ខណៈចាំបាច់របស់វា។

**ទំនាក់ទំនងសាធារណៈ៖** ត្រូវប្រកាន់ខ្ជាប់នូវគុណតម្លៃនៃកិត្តិនាមនិងកេរ្តិ៍ឈ្មោះរបស់យើង នៅពេលណាដែលយើង តំណាងឱ្យធនាគារ ABA ។ ប្រសិនបើអ្នកទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ ឬការផ្ដល់ព័ត៌មានសម្រាប់ ទំនាក់ទំនងសាធារណៈនោះ អ្នកត្រូវប្រាកដថាការបង្ហាញព័ត៌មាននេះមាន ភាពត្រឹមត្រូវ ដែលអាចទុកចិត្តបាន និងមានភាពពេញលេញ។

**ភាពត្រឹមត្រូវ និងតម្លាភាពផ្នែកហិរញ្ញវត្ថុ៖** យើងទទួលខុសត្រូវ និងធានាថាស្ថានភាព និងកំណត់ត្រាហិរញ្ញវត្ថុ របស់ធនាគារ ABA មានភាពពេញលេញ យុត្តិធម៌ ត្រឹមត្រូវ និងទៀងទាត់ពេលវេលា និងជាការឆ្លុះបញ្ចាំងដែលអាចយល់បានអំពីប្រតិបត្តិការ និងសកម្មភាពអាជីវកម្មរបស់ធនាគារ ABA។

**ការចៀសវាងទំនាស់ផលប្រយោជន៍៖** បុគ្គលិករបស់យើងមិនត្រូវចូលរួមដោយផ្ទាល់ ឬដោយប្រយោលនៅក្នុង សកម្មភាពអាជីវកម្មណាមួយដែលប្រកួតប្រជែង ឬផ្ទុយនឹងផលប្រយោជន៍របស់ធនាគារឡើយ។ ប្រសិនបើបុគ្គលិករបស់យើងមានផលប្រយោជន៍ហិរញ្ញវត្ថុជាមួយចំពោះអតិថិជន មិនថាជាទំនាក់ទំនង គ្រួសារ ដៃគូ ភាគទុនិក និង/ឬឥណទានយកនោះទេ ផលប្រយោជន៍នោះគួរតែត្រូវបាន លាតត្រដាងភ្លាមៗ ទៅអ្នកគ្រប់គ្រងផ្ទាល់របស់ បុគ្គលិកដើម្បីរាយការណ៍ទៅថ្នាក់ដឹកនាំកំពូល របស់ធនាគារ។

**សកម្មភាពខាងក្រៅ៖** មុនពេលធ្វើការលះបង់ណាមួយ ឬមុនពេលទទួលយកការងារក្រៅម៉ោង ឬសកម្មភាព អាជីវកម្មផ្សេងទៀត នៅខាងក្រៅម៉ោងធ្វើការរបស់ធនាគារ ត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សររបស់ នាយកដ្ឋានធនធានមនុស្ស ឬបុគ្គលដែលត្រូវបានចាត់តាំងផ្សេងទៀតមុនពេល បុគ្គលិកចាប់ផ្ដើម ធ្វើការក្រៅម៉ោង ឬសកម្មភាពអាជីវកម្មផ្សេងទៀត។

**ការធ្វើកំណែទម្រង់៖** ដើម្បីលើកកម្ពស់ យើងប្រើប្រាស់ការរកឃើញរបស់យើងលើគុណវិបត្តិ និងភាពខ្វះខាតនៅក្នុងអាជីវកម្មរបស់យើងតាមរយៈមតិរបស់អតិថិជន ការធ្វើសវនកម្មផ្ទៃក្នុង ការប្រតិបត្តិតាម និងនីតិវិធីគ្រប់គ្រង ហានិភ័យ សវនករ និងនិយ័តករខាងក្រៅ ក៏ដូចជាទីប្រឹក្សា និងពិគ្រោះឯករាជ្យ។

## យើងរួមចំណែកចំពោះជោគវាសនារបស់ប្រទេស

**ការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន៖** ចំពោះយើង ទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម មានន័យថាសម្រេច បាននូវភាពជោគជ័យក្នុងអាជីវកម្មដោយបង្ហាញពីសេចក្ដីគោរព និងការចូលរួមចំណែកដល់ប្រជាជនក្នុងប្រទេស និងពិភពលោក។ យើងលើកកម្ពស់គោលការណ៍សិទ្ធិមនុស្សដែលទទួលយកជាទូទៅ និងគុណតម្លៃសាជីវកម្មរបស់យើង រួមទាំងបទដ្ឋានសីលធម៌ខ្ពស់ផងដែរ។

**ការគ្រប់គ្រងបរិស្ថាន និងការប្រតិបត្តិតាម៖** ច្បាប់បរិស្ថាន ស្តង់ដារ តម្រូវការនិងគោលនយោបាយបរិស្ថាន មួយចំនួនដាក់ធ្វើអោយការអនុវត្តចំពោះប្រតិបត្តិការ ការអនុវត្ត និងផលិតផលនៃអាជីវកម្មរបស់យើង។ បញ្ជីនៃការមិនរាប់បញ្ចូលរបស់យើងលើសកម្មភាពផ្តល់ប្រាក់កម្ចី និងបញ្ជីលើសកម្មភាពហាមឃាត់នានា នៃធនាគារ ABA ក្នុងការដោះស្រាយអាជីវកម្មដែលមានគ្រោះថ្នាក់ដល់បរិស្ថានដូចជាការកាប់ឈើ និងការបូមខ្សាច់ ជាដើម។

**អាជីវកម្មដែលមិនពាក់ព័ន្ធនយោបាយ៖** ខណៈដែលយើងគាំទ្រសេរីភាពនយោបាយរបស់បុគ្គលិក ដោយផ្អែកលើ មូលដ្ឋានបុគ្គល ក្នុងនាមជាធនាគារ យើងមិនចូលរួមក្នុងសកម្មភាពនយោបាយណាមួយ ដូចជាការផ្តល់ហិរញ្ញប្បទានដល់យុទ្ធនាការបោះឆ្នោត ការបញ្ចុះបញ្ចូល ឬផ្សព្វផ្សាយការពេញចិត្តផ្នែកនយោបាយរបស់យើងតាមមធ្យោបាយណាមួយនោះទេ។ យើងចង់ឱ្យមានការប្រកួតប្រជែងនយោបាយ ត្រឹមត្រូវ និងយុត្តិធម៌នៅក្នុង ព្រំដែននៃច្បាប់កម្ពុជា។ យើងនឹងគោរពអំណាចនយោបាយណាមួយដែល ឈ្នះជាផ្លូវការ ក្នុងការប្រកួតប្រជែងដោយចំហ និងយុត្តិធម៌។

## ការរំលឹកលើការសួរសំណួរ និងការរាយការណ៍

ដើម្បីអនុវត្តតាមក្រមនេះ ដោយប្រកាន់ខ្ជាប់សុចរិតភាព និងវិជ្ជាជីវៈ បុគ្គលិកគ្រប់រូបមានកាតព្វកិច្ចក្នុងការរាយការណ៍ទៅអ្នកគ្រប់គ្រងរបស់ខ្លួន និង/ឬនាយកដ្ឋានប្រតិបត្តិតាមបទប្បញ្ញត្តិ អំពីការរំលោភបំពានណាមួយលើច្បាប់ ក្រមប្រតិបត្តិ និងគោលការណ៍ណែនាំផ្សេងទៀតរបស់ក្រុមហ៊ុន។ បុគ្គលិកទាំងអស់របស់ធនាគារ ABA ត្រូវបានលើកទឹកចិត្តឱ្យសួរសំណួរ ឬលើកឡើងនូវក្តីកង្វល់ទៅកាន់អ្នកគ្រប់គ្រង ឬអ្នកឯកទេសផ្ទាល់របស់ពួកគេដែលមានជំនាញក្នុងការដោះស្រាយសំនួរ ឬបញ្ហាបែបនេះ រួមមាននាយកដ្ឋានធនធានមនុស្ស នាយកដ្ឋានប្រតិបត្តិតាម ហានិភ័យ ច្បាប់ និងនាយកដ្ឋានសន្តិសុខ។

## ខ. ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

ក្រុមប្រឹក្សាភិបាលបានអនុម័តក្រមនេះ ហើយបានអនុវត្តចាប់ពីឆ្នាំ ២០១៥។

## គ. យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

ដើម្បីធានាថាបុគ្គលិកទាំងអស់បានយល់ដឹងអំពីក្រមនេះ ធនាគារមានកម្មវិធីផ្ទាល់ខ្លួន គឺតម្រូវអោយបុគ្គលិកទាំងអស់ អាននិងបញ្ជាក់ថាបានយល់ដឹង ដែលវាត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ។ បន្ថែមពីលើនេះទៀត ធនាគារមានកម្មវិធីបណ្តុះបណ្តាលដល់បុគ្គលិកក្នុងអំឡុងពេល៣ខែដំបូងពីថ្ងៃចាប់ផ្តើមការងារ និងមានកម្មវិធីបណ្តុះបណ្តាលរំលឹកឡើងវិញជារៀងរាល់ឆ្នាំ។

ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន នាយកដ្ឋានប្រតិបត្តិតាមរបស់ធនាគារ ធ្វើការតាមដានលើអនុលោមភាព ក៏ដូចជាការបំពានលើច្បាប់ និងបទប្បញ្ញត្តិ រួមទាំងក្រមដែលបានអនុម័តផងដែរ។ លើសពីនេះ នីតិវិធីវិស្សលប្លឺវីងរបស់ធនាគារ បានអនុញ្ញាតឱ្យបុគ្គលិករាយការណ៍ រាល់ការសង្ស័យចំពោះការបំពានលើក្រមនេះ។ បុគ្គលិកដែលបានបំពានមកលើក្រមនេះ ត្រូវប្រឈមមុខនឹងការពិន័យ ដូចជាការបញ្ឈប់ពីការងារជាដើម។

## ឃ.ប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

### ១. គោលនយោបាយរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ សម្រាប់គ្រប់គ្រងលើប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

| ល.រ | ភាគីជាប់ពាក់ព័ន្ធ | គោលនយោបាយ |
|---|---|---|
| ១ | ក្រុមហ៊ុនហូលឌីង | គ្មាន |
| ២ | កិច្ចព្រមព្រៀងវិនិយោគចម្រុះ | គ្មាន |
| ៣ | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | គ្មាន |
| ៤ | ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងច្រើនលើសលុប | គោលនយោបាយប្រតិបត្តិការ ជាមួយភាគីជាប់ពាក់ព័ន្ធ |

| ល.រ | ភាគីជាប់ពាក់ព័ន្ធ | គោលនយោបាយ |
|---|---|---|
| ៥ | អភិបាល និងសមាជិកគ្រួសារផ្ទាល់របស់អភិបាល | គោលនយោបាយប្រតិបត្តិការ ជាមួយភាគីជាប់ពាក់ព័ន្ធ |
| ៦ | បុគ្គលិក និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលិក | គោលនយោបាយប្រតិបត្តិការ ជាមួយភាគីជាប់ពាក់ព័ន្ធ |
| ៧ | ផ្សេងៗ | គ្មាន |

ធនាគារ ABA គោរពតាមនិយមន័យនៃភាគីជាប់ពាក់ព័ន្ធដែលមានរៀបរាប់នៅក្នុងច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ហើយគោលនយោបាយប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ធនាគារ ABA ក៏បានរៀបចំផងដែរនូវឯកសារថ្លៃផ្ទេរ (Transfer Pricing Document) ដើម្បីធានាថារាល់ប្រតិបត្តិការរបស់ភាគីជាប់ពាក់ព័ន្ធគោរពតាមគោលការណ៍ជំហោងដៃ (Arm's Length Principle) ស្របតាមតម្រូវការពីអគ្គនាយកដ្ឋានពន្ធដារ។

## ២. ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធ

| ល.រ | ឈ្មោះភាគីជាប់ពាក់ព័ន្ធ | ប្រភេទប្រតិបត្តិការ | ទំហំប្រតិបត្តិការ | សង្ខេបអំពីប្រតិបត្តិការ |
|---|---|---|---|---|
| ១ | ធនាគារជាតិកាណាដា | ប្រាក់បញ្ញើ | ១៨៥.៧០៣.៣០១ ដុល្លារអាមេរិក | ធនាគារបានដាក់ប្រាក់បញ្ញើនៅធនាគារជាតិកាណាដាចំនួន ១៨៦លានដុល្លារអាមេរិក ក្នុងរយៈពេល ១ខែ ដែលទទួលបានអត្រាការប្រាក់ ០,៤% ក្នុង ១ឆ្នាំ |
| | | បំណុលបន្ទាប់បន្សំ | ១៤៨.០២៧.៩៦២ ដុល្លារអាមេរិក | ធនាគារបានខ្ចីប្រាក់ចំនួន ១៤៨លានដុល្លារអាមេរិកពីក្រុមហ៊ុនមេ (ដែលមានឈ្មោះថា ធនាគារជាតិកាណាដា) ដែលជាបំណុលបន្ទាប់បន្សំ |

សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមពិនិត្យកំណត់សម្គាល់ ៣១ "សម្ព័ន្ធញាតិ" នៃរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច និងត្រូវពិនិត្យដោយសវនករឯករាជ្យ។

ចន្លោះនេះទុកទំនេរ

# ផ្នែកទី ៤

## ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង ការធ្វើសវនកម្ម

## ក. សង្ខេបអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬគោលនយោបាយគ្រប់គ្រងហានិភ័យ

ធនាគារមានប្រព័ន្ធគ្រប់គ្រងហានិភ័យពេញលេញដែលអនុលោមតាមលក្ខខណ្ឌបទប្បញ្ញត្តិតម្រូវដោយធនាគារជាតិនៃ កម្ពុជា ស្តង់ដារគ្រប់គ្រងហានិភ័យរបស់ធនាគារជាតិនៃកាណាដា និងការអនុវត្តដ៏ល្អជាអន្តរជាតិ។ នៅចុងឆ្នាំ ២០២០ មុខងារហានិភ័យត្រូវបានពង្រឹងដោយមានការតែងតាំងនាយកហានិភ័យនិងប្រតិបត្តិតាម។

នេះជាឋានានុក្រមនៃប្រព័ន្ធគ្រប់គ្រងហានិភ័យនៅធនាគារអេប៊ីអេ (ABA):

១. ក្រុមប្រឹក្សាភិបាល អនុម័តលើវីសអាប់ភែថាយ (Risk Appetite) និងគោលនយោបាយហានិភ័យ។

២. គណៈកម្មាធិការគ្រប់គ្រងហានិភ័យជាន់ខ្ពស់ ជាក្រុមដែលអនុម័តមុនគេលើវីសអាប់ភែថាយ (Risk Appetite) និងគោល នយោបាយហានិភ័យ វិភាគលើរបាយការណ៍ហានិភ័យប្រចាំត្រីមាស ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល ពាក់ព័ន្ធនឹងការ គ្រប់គ្រងហានិភ័យ និងដាក់កម្រិតលើគណៈប្រតិបត្តិ។

៣. គណៈកម្មាធិការប្រតិបត្តិតាម គ្រប់គ្រងហានិភ័យផ្សេងៗគ្នា រាប់ចាប់ពីគណៈកម្មាធិការឥណទាន (គ្រប់គ្រងហានិភ័យឥណទាន) គណៈកម្មាធិការទ្រព្យសកម្ម/ទ្រព្យអកម្ម (គ្រប់គ្រងហានិភ័យទីផ្សារនិងសន្ទនីយភាព) គណៈកម្មាធិការព័ត៌មាន វិទ្យានិង បច្ចេកវិទ្យាឌីជីថល (គ្រប់គ្រងហានិភ័យសុវត្ថិភាពអ៊ីនធឺនេត និងព័ត៌មានវិទ្យា) គណៈកម្មាធិការហានិភ័យកិត្តិស័ព្ទ និងប្រតិបត្តិការ (គ្រប់គ្រងហានិភ័យប្រតិបត្តិការ)។ គណៈកម្មាធិការទាំងនេះអនុម័តលើគោលការណ៍ហានិភ័យ ដាក់កម្រិត និងទទួលយក ផែនការសកម្មភាពដើម្បីកាត់បន្ថយហានិភ័យ។

៤. នាយកដ្ឋានសវនកម្មទទួលខុសត្រូវលើការវាយតម្លៃដោយឯករាជ្យទៅលើប្រព័ន្ធគ្រប់គ្រងហានិភ័យនៅធនាគារអេប៊ីអេ (ABA) ក្នុងនាមជាខ្សែបន្ទាត់ការពារទី៣ ហើយរាយការណ៍ជូនក្រុមប្រឹក្សាភិបាល។

នាយកដ្ឋានគ្រប់គ្រងហានិភ័យដែលមានផ្នែកឥណទាន ហិរញ្ញវត្ថុ និងប្រតិបត្តិការ ទទួលខុសត្រូវលើដំណើរការគ្រប់ គ្រងហានិភ័យ ក្នុងនាមជាខ្សែបន្ទាត់ការពារទី២ ហើយរាយការណ៍ប្រចាំត្រីមាស ជូនគណៈកម្មាធិការគ្រប់គ្រងហានិភ័យ ជាន់ខ្ពស់។

## ខ. សង្ខេបអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

- ការគ្រប់គ្រងផ្ទៃក្នុងជាដំណើរការមួយមានប្រសិទ្ធភាពចំពោះក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងប្រតិបត្តិ និងបុគ្គលិកគ្រប់កម្រិតទាំងអស់នៃធនាគារ ហើយប្រតិបត្តិការបន្តបន្ទាប់
- ជាពិសេស វាជាប្រព័ន្ធនៃនីតិវិធី និងគោលនយោបាយនៃការគ្រប់គ្រងផ្ទៃក្នុងដែលផ្តល់ឲ្យធនាគារនូវភាពងាយស្រួលចំពោះ៖

  ក) ការសម្រេចនូវគោលដៅយុទ្ធសាស្ត្ររបស់ខ្លួន

  ខ) រក្សាការអនុវត្តហិរញ្ញវត្ថុរឹងមាំ

  គ) របាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍គណៈគ្រប់គ្រងដែលអាចទុកចិត្តបាន

  ឃ) ការប្រតិបត្តិតាមច្បាប់ និងបទប្បញ្ញត្តិនានា ព្រមទាំងបទប្បញ្ញត្តិផ្ទៃ ក្នុងរបស់ធនាគារផងដែរ

  ង) ការកាត់បន្ថយហានិភ័យនៃការខាតបង់ និងហានិភ័យកេរ្តិ៍ឈ្មោះ

- នៅធនាគារ ABA ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់បង្កើតវប្បធម៌សមស្របដើម្បីសម្រួលដល់ដំណើរ
- ការគ្រប់គ្រងផ្ទៃ ក្នុងប្រកបដោយប្រសិទ្ធភាព និងដើម្បីត្រួតពិនិត្យប្រសិទ្ធភាពនៃដំណើរការនេះជាបន្តបន្ទាប់។ ទន្ទឹមនឹងនេះ បុគ្គលនីមួយៗនៅក្នុងធនាគារ ABA ចូលរួមក្នុងដំណើរការនេះដែរ
- គោលនយោបាយសំខាន់ៗពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលដែលរួមបញ្ចូលទាំងមុខងារគ្រប់គ្រងអចិន្ត្រៃយ៍ និងជាប្រចាំ
- ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាលនេះធ្វើការប្រជុំទៀងទាត់យ៉ាងហោចណាស់រៀងរាល់ត្រីមាសម្តង។

អំឡុងពេលកិច្ចប្រជុំគណៈកម្មាធិការធ្វើការពិនិត្យ និង អនុម័តគោលនយោបាយមួយចំនួនដែលជាផ្នែកនៃប្រព័ន្ធ គ្រប់គ្រងផ្ទៃក្នុងរបស់ធនាគារ។

## គ. ការធ្វើសវនកម្ម

### ១. សវនកម្មផ្ទៃក្នុង

#### ១.១. តួនាទីនិងការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុង

នាយកដ្ឋានសវនកម្មផ្ទៃក្នុងទទួលខុសត្រូវ លើការអនុវត្តមុខងារសវនកម្មផ្ទៃក្នុងដែលត្រូវបានចាត់តាំងដោយគណៈកម្មាធិការសវនកម្មដែលរួមមានដូចខាងក្រោម៖

- ការរៀបចំរួមមានការធ្វើកម្មវិធីសវនកម្មធ្វើផែនការបែងចែងធនធានរៀបចំថវិការនិងស្នើសុំការអនុម័តពីគណៈកម្មាធិការសវនកម្ម
- អនុវត្តតេស្តសវនកម្មផ្ទៃក្នុងផ្អែកតាមផែនការសវនកម្មនិងសេចក្តីណែនាំគណៈកម្មាធិការសវនកម្ម
- ធ្វើតេស្តវាយតម្លៃនិងផ្តល់អនុសាសន៍លើប្រសិទ្ធភាព និងប្រសិទ្ធផលនៃប្រព័ន្ធត្រួតពិនិត្យជាពិសេសវត្តមានភាព និងកម្មវិធីនៃឧបករណ៍ដូចជានីតិវិធី និងដំណើរការនៃការបែកចែកតួនាទីនិងកាតព្វកិច្ចការគ្រប់គ្រងទ្វេមុខ ការអនុញ្ញាត ការអនុម័ត ដានសវនកម្ម ការរាយការណ៍សុវត្ថិភាពព័ត៌មាន និងផ្សេងៗ
- តេស្តវាយតម្លៃនិងផ្តល់ អនុសាសន៍ លើ ប្រសិទ្ធភាព និង ប្រសិទ្ធផល នៃប្រព័ន្ធគ្រប់គ្រងហានិភ័យជា ពិសេសវត្តមានភាព និង កម្មវិធីនៃឧបករណ៍ ក្នុងការកំណត់ អត្តសញ្ញាណការវាស់ស្ទង់ការត្រួតពិនិត្យតាមដាននិងការកាត់បន្ថយ
- តេស្តវាយតម្លៃនិងផ្តល់អនុសាសន៍លើប្រសិទ្ធភាព  និងប្រសិទ្ធផលនៃអភិបាលកិច្ចសាជីវកម្មនិងមុខងារត្រួតពិនិត្យការប្រតិបត្តិតាមជាពិសេសបុគ្គលិក និងដំណើរការធុរកិច្ចរបស់ធនាគារ ស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ឯកសារផ្ទៃក្នុង និងបទប្បញ្ញត្តិដទៃទៀត
- តេស្តវាយតម្លៃនិងផ្តល់អនុសាសន៍លើប្រសិទ្ធភាព និងប្រសិទ្ធផលនៃការប្រតិបត្តិតាមមុខងារ AML/CFT ជាពិសេសវត្តមានភាព និងកម្មវិធីនៃឧបករណ៍កំណត់អត្តសញ្ញាណប្រតិបត្តិការសង្ស័យ និងប្រតិបត្តិការហានិភ័យខ្ពស់ការយកចិត្តទុកដាក់ស្គាល់អតិថិជនសកម្មភាពកែកំហុស ឬបញ្ចប់ទំនាក់ទំនងជាមួយអតិថិជនហានិភ័យ ដោយរាយការណ៍ជូនទៅនិយ័តករ និងថ្នាក់ដឹកនាំជាន់ខ្ពស់
- ការពារពីការក្លែងបន្លំផ្ទៃក្នុង  ឬការរំលោភសេចក្តីទុកចិត្តផ្សេងៗទៀតដោយបុគ្គលិកផ្ទៃក្នុងតាមរយៈសវនកម្មទៀងទាត់ និងសវនកម្មឥតគ្រោងទុក។

#### ១.២. ការតែងតាំងថ្មី និងការដកចេញ/ការលាឈប់របស់ប្រធាន និង/ឬអនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង

ក្នុងឆ្នាំ២០២១ មិនមានការលាឈប់ ឬការតែងតាំងថ្មីនូវប្រធាន និង/ឬអនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងទេ។

### ២. សវនកម្មខាងក្រៅ

| ល.រ | ឈ្មោះក្រុមហ៊ុន | កាលបរិច្ឆេទជ្រើសតាំង | តម្លៃសេវាសវនកម្ម | តម្លៃសេវា មិនមែនសវនកម្ម |
|---|---|---|---|---|
| ១ | ឌីឡយ្ធ័ (ខេមបូឌា) ខូអិលធីឌី | ៦ មិថុនា ២០១៩ (សវនកម្មប្រចាំឆ្នាំ)និង ២៩ មីនា ២០២១ (ការពិនិត្យត្រីមាស ១-៤ ២០២១) | ១២២,០០០ដុល្លាអាមេរិក (មិនទាន់គិតពន្ធ) | គ្មាន |

# ផ្នែកទី ៥

## ភាពជាដៃគូ

## ក. បង្ហាញពីគោលនយោបាយ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោម៖

| ល.រ | ខ្លឹមសារ | គោលនយោបាយ | សកម្មភាព |
|---|---|---|---|
| ១ | ការជ្រើសរើសអ្នកផ្គត់ផ្គង់/អ្នកម៉ៅការ | នីតិវិធីរដ្ឋបាល | ការដេញថ្លៃទៀងទាត់ដើម្បីកំណត់រកភាគីផ្គត់ផ្គង់ល្អបំផុតសម្រាប់ធនាគារ |
| ២ | ការគ្រប់គ្រង និងការការពារនិយោជិត | ▪ កម្មវិធីធានារ៉ាប់រងអាយុជីវិត<br>▪ ការធានារ៉ាប់រង ប.ស.ស<br>▪ ក្រមប្រតិបត្តិធុរកិច្ច និងសីលធម៌វិជ្ជាជីវៈ<br>▪ គោលការណ៍ណែនាំអំពីទំនាស់ផលប្រយោជន៍<br>▪ កម្មវិធីលើកទឹកចិត្តសមត្ថភាពការងារ<br>▪ នីតិវិធីវិស្សមកាលប្រចាំឆ្នាំ<br>▪ គោលការណ៍ណែនាំកម្ចីបុគ្គលិក | ការបណ្តុះបណ្តាលបុគ្គលិកទៀងទាត់អំពីក្រមប្រតិបត្តិធុរកិច្ច និងសីលធម៌វិជ្ជាជីវៈ នីតិវិធីវិស្សមកាលប្រចាំឆ្នាំ គោលការណ៍ណែនាំអំពីកម្ចីបុគ្គលិក។ សកម្មភាពនានាអំពីគោលនយោបាយផ្សេងៗត្រូវបានអនុវត្តប្រចាំថ្ងៃ និងនៅពេលចាំបាច់។ |
| ៣ | ការគាំពារបរិស្ថាន | បញ្ជីអាជីវកម្ម និងសកម្មភាពត្រូវបានហាមឃាត់ក្នុងការផ្តល់កម្ចី | ក្នុងអាជីវកម្មរបស់ខ្លួន ធនាគារមិនផ្តល់កម្ចីដល់អាជីវកម្មមួយចំនួនដែលត្រូវបានធនាគារចាត់ទុកថាមានគ្រោះថ្នាក់ដល់បរិស្ថាន ឬសុខុមាលភាពរបស់ប្រជាជនកម្ពុជា។ ការស្វែងរកសកម្មភាពទាំងនេះត្រូវបានធ្វើឡើងជារៀងរាល់ថ្ងៃនៅដំណាក់កាលវិភាគការស្នើសុំកម្ចី។ |
| ៤ | អន្តរកម្មជាមួយសហគមន៍ | គោលនយោបាយទំនួលខុសត្រូវរបស់សាជីវកម្មចំពោះសង្គម | សូមមើលផ្នែក ខ សម្រាប់បញ្ជីសកម្មភាពទំនួលខុសត្រូវសាជីវកម្មចំពោះសង្គមរបស់ធនាគារ ក្នុងឆ្នាំ ២០២១។ |
| ៥ | ការការពារសិទ្ធិម្ចាស់បំណុល | កិច្ចព្រមព្រៀងអ្នកតំណាងម្ចាស់សញ្ញាបណ្ណ | ចែងពីសិទ្ធិ និងកាតព្វកិច្ចរបស់ម្ចាស់សញ្ញាបណ្ណនៃសញ្ញាបណ្ណដែលប្រតិបត្តិតាមបញ្ញត្តិរបស់ ន.ម.ក នៅកាលបរិច្ឆេទទូទាត់ រួមមាន ការកែប្រែណាមួយផ្សេងដែលអនុលោមតាមកិច្ចព្រមព្រៀងនេះ។ ប្រសិនបើមានភាពខុសគ្នារវាងលក្ខន្តិកៈនៃសញ្ញាបណ្ណ និងកិច្ចព្រមព្រៀងអ្នកតំណាងម្ចាស់សញ្ញាបណ្ណនោះកិច្ចព្រមព្រៀងអ្នកតំណាងម្ចាស់សញ្ញាបណ្ណនឹងត្រូវអនុវត្ត។ |
| ៦ | កម្មវិធីប្រយុទ្ធប្រឆាំងអំពើពុករលួយ | ក្រមប្រតិបត្តិធុរកិច្ចនិងសីលធម៌វិជ្ជាជីវៈ | ការបណ្តុះបណ្តាលទៀងទាត់ដល់បុគ្គលិកទាំងអស់អំពីគោលនយោបាយប្រឆាំងនឹងការសូកប៉ាន់ និងអំណោយរបស់ធនាគារ។ |

## ខ. ពិពណ៌នាអំពីទំនួលខុសត្រូវសង្គម៖

| ល.រ | អ្នកទទួលផលប្រយោជន៍ | គោលបំណងនៃការបរិច្ចាគ |
|---|---|---|
| ១ | អង្គការ EmbraceAbility NPO | ដើម្បីលើកកម្ពស់ភាពអង់អាចនៃសហគមន៍ និងបរិយាបន្នតាមរយៈពេលការអប់រំ និងកីឡា និងលើកកម្ពស់សិទ្ធិរបស់ជនពិការ ABA បានបរិច្ចាគទឹកប្រាក់ ៥,០០០ ដុល្លារអាមេរិក និងផ្តល់ការគាំទ្រផ្នែកសម្ភារៈជូនអង្គការ EmbraceAbility ដែលជាអង្គការឯករាជ្យមិនរកប្រាក់កម្រៃ។ |
| ២ | មូលនិធិជំនួយប្រយុទ្ធប្រឆាំងកូវីដ១៩ | ដើម្បីគាំទ្រនូវកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ ក្នុងប្រទេស ដែលបានរាលដាលចូលក្នុង សហគមន៍ ធនាគារ ABA បានបរិច្ចាគទឹកប្រាក់ ១ លានដុល្លារអាមេរិក (ប្រមាណ ៤ ពាន់លានរៀល) ។ |
| ៣ | អង្គការបេះដូងតូច | ធនាគារ ABA បានបរិច្ចាគទឹកប្រាក់ ៣,០០០ ដុល្លារអាមេរិក ជូនអង្គការបេះដូងតូច សម្រាប់គាំទ្រដល់កុមារក្រីក្រ និងអនាថា។ |
| ៤ | អង្គការ Sipar | Sipar's Youth Employability ដែលជាគម្រោងរបស់ក្រសួងអប់រំ យុវជន និងកីឡា និង Sipar និងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) មានគោលបំណងពង្រឹងការចូលរួមរបស់យុវជនកម្ពុជាក្នុងវិស័យសង្គមស៊ីវិលក្នុងបរិបទក្រោយកូវីដ១៩។ ធនាគារ ABA បានបរិច្ចាគសម្ភារៈសិក្សា និងសម្ភារៈ អានដើម្បីលើកកម្ពស់អក្ខរកម្ម និងលទ្ធភាពការងាររបស់ជនក្រីក្រ។ |
| ៥ | កីឡាវាយកូនបាល់កម្ពុជា | ធនាគារបានបរិច្ចាគទឹកប្រាក់ ១០,០០០ ដុល្លារអាមេរិកដើម្បីគាំទ្រដល់ ក្រុមជម្រើសជាតិវាយកូនបាល់កម្ពុជាទៅចូលរួមក្នុងព្រឹត្តិការណ៍ Davis Cup 2021 នៅប្រទេសបារ៉ែន ក៏ដូចជាលើកកម្ពស់ចលនាកីឡាបាយកូនបាល់ និងវប្បធម៌លេងកីឡារបស់ប្រទេសបន្ថែម។ |

ចន្លោះនេះទុកទំនេរ

# ផ្នែកទី ៦

## ការបង្ហាញព័ត៌មាន និងតម្លាភាព

## ក. បង្ហាញអំពីព័ត៌មានក្នុងរបាយការណ៍ប្រចាំឆ្នាំដូចខាងក្រោម៖

| ល.រ | ព័ត៌មាន | មាន/គ្មានបង្ហាញ |
|---|---|---|
| ១ | ចក្ខុវិស័យ/បេសកកម្ម/គោលដៅអាជីវកម្ម | មាន |
| ២ | សូចនាករហិរញ្ញវត្ថុ | មាន |
| ៣ | សូចនាករមិនមែនហិរញ្ញវត្ថុ | មាន |
| ៤ | កត្តាហានិភ័យសំខាន់ៗ | មាន |
| ៥ | គោលនយោបាយភាគលាភ | មាន |
| ៦ | ជីវប្រវត្តិរបស់អភិបាល | មាន |
| ៧ | ការបណ្តុះបណ្តាលសម្រាប់អភិបាល | គ្មាន[២] |
| ៨ | ចំនួនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មាន |
| ៩ | វត្តមានរបស់អភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មាន |
| ១០ | លាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ | មាន |

[២] អំឡុងពេលរបាយការណ៍នេះ មិនមានការបណ្តុះបណ្តាលសម្រាប់អភិបាលទេ។

## ខ. ពិពណ៌នាអំពីយន្តការនៃការបង្ហាញព័ត៌មាន ដោយរៀបរាប់ពីមធ្យោបាយ នីតិវិធី និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន

ផ្អែកលើប្រកាស ០០៧/១៨ គ.ម.ក/ប្រ.ក ចុះកាលបរិច្ឆេទថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០១៨ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម ធនាគារ ABA បានតែងតាំងមន្ត្រីបង្ហាញព័ត៌មាន និងជំនួយការមន្ត្រីបង្ហាញព័ត៌មាន ដូចខាងក្រោម៖

### មន្ត្រីបង្ហាញព័ត៌មាន

| ល.រ | ឈ្មោះ | មុខតំណែង |
|---|---|---|
| ១ | លោក Babu Ram Gyawali | នាយកហិរញ្ញវត្ថុ |
| ២ | លោក Zhiger Atchabarov | នាយកប្រតិបត្តិការអន្តរជាតិ |
| ៣ | លោក គង់ សាមាន | ប្រធាននាយកដ្ឋានរតនាភិបាល |
| ៤ | លោក តុល ភីរិទ្ធ | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ |

### ជំនួយការមន្ត្រីបង្ហាញព័ត៌មាន

| ល.រ | ឈ្មោះ | មុខតំណែង |
|---|---|---|
| ១ | លោក ជា បញ្ញនៈ | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ |
| ២ | លោក ផុល សុជា | អនុប្រធាននាយកដ្ឋានរតនាភិបាល |
| ៣ | កញ្ញា ឡាយ ជីវម៉ី | ប្រធានផ្នែកបង្ហាញព័ត៌មានសាជីវកម្ម |

## គ. ទំនាក់ទំនងជាមួយវិនិយោគិន

### ១. បង្ហាញពីយន្តការ និងនីតិវិធីនៃការទំនាក់ទំនងជាមួយវិនិយោគិន

ធនាគារ ABA ស្វាគមន៍វិនិយោគិន និងផ្តល់ព័ត៌មានចាំបាច់អំពីសកម្មភាព និងប្រតិបត្តិការហិរញ្ញវត្ថុរបស់ខ្លួននៅលើវិបសាយសាជីវកម្មរបស់ខ្លួន៖ https://www.ababank.com/about-aba/for-investors/

### ២. ពិពណ៌នាដោយសង្ខេបអំពីទំនាក់ទំនងជាមួយនឹងវិនិយោគិនក្នុងរយៈពេល១(មួយ)ឆ្នាំចុងក្រោយ

នៅឆ្នាំ ២០២១ ធនាគារ ABA បានបំពេញកាតព្វកិច្ចរបស់ខ្លួនហើយបានផ្ទេរការទូទាត់ការប្រាក់លើកទីមួយនិងទីពីរនៃសញ្ញាបណ្ណសាជីវកម្មដល់ម្ចាស់ភាគហ៊ុនរបស់ខ្លួននៅខែកុម្ភៈនិងសីហាតាមរយៈធនាគារអេស៊ីលីដា ភីអិលស៊ី ដែលដើរតួជាភ្នាក់ងារទូទាត់ប្រាក់។ ថវិកាសរុបចំនួន ៦.៥៦១.៨៨៧.៦៦០ រៀល (ប្រមាណ ១,៦១ លានដុល្លារអាមេរិក) ត្រូវបានបង់ទៅឲ្យម្ចាស់សញ្ញាបណ្ណចំនួន ៦៨ នាក់ជាការប្រាក់ប្រចាំឆ្នាំ។

លើសពីនេះទៀតធនាគារបានបើកគណនីឆ្លើយឆ្លងជាប្រាក់ថៃបាត (ធនាគារ Kasikornbank Public Company Limited, ប្រទេសថៃ) វៀតណាមដុង (ធនាគារ Vietcom) និងយ៉េនជប៉ុន (ធនាគារ Sumitomo Mitsui Banking Corporation) ជាការឆ្លើយតបទៅនឹងកំណើនតម្រូវការរបស់អតិថិជន។

អ្នកជំនាញទំនាក់ទំនងវិនិយោគិនរបស់ធនាគារក៏ទំនាក់ទំនងជាមួយអ្នកផ្តល់កម្ចីសក្តានុពលសម្រាប់ការខ្ចីអន្តរជាតិពេញមួយឆ្នាំ។

ចន្លោះនេះទុកទំនេរ

ABA BANK

NATIONAL BANK OF CANADA GROUP

អគារលេខ១៤១, ១៤៦, ១៤៨ និង១៤៨ អា បេ សេ ដេ វិថីព្រះសីហនុ និងអគារលេខ១៤៥
និង១៥៣ អា បេ សេ ផ្លូវលេខ២៧៨ និង ផ្ទះលេខ ១៧១ ផ្លូវត្រសក់ផ្អែម ភូមិ៤
សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

(+៨៥៥) ២៣ ២២៥ ៣៣៣ | ទូរសារ: (+៨៥៥) ២៣ ២១៦ ៣៣៣
info@ababank.com | www.ababank.com